សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការចាត់ចែងក្បួនការពារ និងការរឹបអូសជាបណ្ដោះអាសន្ន

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **សាយ មុន្នី**

លោកស្រី **សុខ សុភាព**

សាស្ត្រាចារ្យណែនាំ

លោក **ញឹក ឧុត្តី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# លិខិតថ្លែងអំណរគុណ

យើងខ្ញុំ ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី ៤ ជំនាន់ទី ១៧ លេខកូតថ្នាក់ L4C3 នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

មាតាបិតា ទាំងទ្វេដែលលោកបានផ្ដល់កំណើតដល់រូបកូន ព្រមទាំងប្រឹងប្រែងគ្រប់បែបយ៉ាង ក្នុងការចិញ្ចឹមបីបាច់ថែរក្សាការពារ អប់រំទូន្មាន ប្រៀនប្រដៅរូបកូន ប្រកបដោយទឹកចិត្តព្រហ្មវិហារធម៌ទាំងបួន។ ជាងនេះទៅទៀតលោកអ្នកដ៏មានគុណទាំងទ្វេ បានខិតខំរកថវិកា មិនខ្លាចនឿយហត់ ទាំងថ្ងៃ ទាំងយប់ ពុះពារប្រឈមមុខរាល់ទុកលំបាកគ្រប់បែបយ៉ាង ធ្វើយ៉ាងណាជម្រុញឲ្យរូបកូនទទួលបានការសិក្សារៀនសូត្រ រហូតដល់បានបញ្ចប់ថ្នាក់ឧត្ដមសិក្សា ដោយទទួលបាននូវលទ្ធផលគួរជាទីមោទនៈបំផុត។

## សូមគោរពនឹងថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅជូន ៖

-**ឯកឧត្ដម សាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចូលរួមរៀបចំឲ្យសាកលវិទ្យាល័យ មានដំណើរការប្រកបដោយជោគជ័យ។ ជាពិសេស លោក លោកស្រី សាស្ត្រាចារ្យ ដែលបានយកចិត្តទុកដាក់ក្នុងការបង្រៀន ដោយមិនខ្លាចនឿយហត់ និងជំរុញផ្នែកស្មារតី ឲ្យយើងខ្ញុំខិតខំរៀនសូត្រ ក្រេបជញ្ជក់យកចំណេះវិជ្ជា។

-ជាពិសេសជាងនេះទៅទៀត សូមធ្វើក្ដីគោរពយ៉ាងធំធេង និងស្មោះអស់ពីដួងចិត្តបំផុត ជូនចំពោះលោកសាស្ត្រាចារ្យ **ញឹក ឧុឃ្ធី** ដែលទទួលបន្ទុកក្នុងការដឹកនាំសារណា ដែលលោកសាស្ត្រាចារ្យបានខិតខំអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងពេលវេលាដ៏មានតម្លៃ និងមមាញឹកផ្ដល់ជាគំនិតផ្ដួចផ្ដើមយ៉ាងច្រើនសន្ធឹកសន្ធាប់ ក្នុងការជម្រុញណែនាំ លើកទឹកចិត្ត និងបានត្រួតពិនិត្យ កែលំអជាច្រើនលើក ច្រើនសារដល់រូបយើងខ្ញុំ ក្នុងការសិក្សាស្រាវជ្រាវ ចងក្រង សរសេរនូវអត្ថបទសារណានេះឡើងរហូតដល់បានបញ្ចប់ជាស្ថាពរ និងប្រកបដោយលទ្ធផលវិជ្ជមាន។

ជាកិច្ចបញ្ចប់នេះ យើងខ្ញុំសូមឱនកាយលើកដៃប្រណមបួងសួងជូនដល់ មាតាបិតា ញាតិមិត្ត ព្រមទាំងថ្នាក់ដឹកនាំសាកលវិទ្យាល័យ លោក លោកស្រីសាស្ត្រាចារ្យ លោកសាស្ត្រាចារ្យដឹកនាំ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ដោយឆ្លងតាមការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានជម្រុញ ក៏ដូចជាផ្តល់ឱកាសឲ្យយើងខ្ញុំ សម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវ និង សរសេរចងក្រង នូវអត្ថបទសារណានេះ ដែលមានចំណងជើងថា "**ការចាត់ចែងរក្សាការពារ**" នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ នេះឡើង ដើម្បីជាស្នាដៃ ជូនដល់សាកលវិទ្យាល័យ និង ដើម្បីទុកសម្រាប់តម្កល់នៃការបញ្ចប់ការសិក្សារបស់យើងខ្ញុំផងដែរ។ តាមរយៈស្នាដៃនេះក៏ជាឯកសារជំនួយដល់មិត្តនិស្សិត អ្នកសិក្សាស្រាវជ្រាវ និង សាធារណៈជនគ្រប់មជ្ឈដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជាទុកជាផ្នែកមួយនៃការស្រាវជ្រាវ។

កិច្ចស្រាវជ្រាវនេះ ចងក្រងឡើងក្នុងបំណង ដើម្បីបង្ហាញអំពីខ្លឹមសារសំខាន់ៗនៅដំណាក់កាលនីមួយៗ ក្នុងការអនុវត្តនាពេលបច្ចុប្បន្ននេះ ក្នុងផ្នែកនីតិវិធីរដ្ឋប្បវេណី ដែលផ្តោតជាសំខាន់លើដំណាក់កាល នៃនីតិវិធីក្នុងការចាត់ចែងរក្សាការពារ។ លើសពីនេះក្នុងអត្ថន័យខ្លឹមសារក៏មានពន្យល់យ៉ាងស៊ីជម្រៅទៅលើ នីតិវិធីនីមួយៗ ដោយចង្អុលបង្ហាញ នូវមាត្រានៃច្បាប់នានាដែលពាក់ព័ន្ធនឹងការរឹបអូសជាបណ្តោះអាសន្ន និង ការចាត់ចែងជាបណ្តោះអាសន្នយ៉ាងលំអិតព្រមទាំងមានភ្ជាប់នូវ ឧទាហរណ៍មួយចំនួន ដែលធ្វើការបកស្រាយទៅលើទ្រឹស្តីសំខាន់ៗ ក្នុងនីតិវិធី។ ទន្ទឹមគ្នានេះផងដែរ ក្នុងការបកស្រាយទៅលើប្រធានបទនេះ ក៏មានបញ្ហាមួយចំនួន ដែលរាំងស្ទះដល់ការបកស្រាយ និង ការអនុវត្តនីតិវិធី ជាក់ស្តែងធ្វើឲ្យមានការលំបាកក្នុងការស្វែងយល់ ដោយសារក្រមនីតិវិធីនេះ មានប្រភពឬសគល់ចេញពីការអនុវត្តក្នុងករណីប្រទេសជប៉ុន។

យើងខ្ញុំសង្ឃឹមថា ស្នាដៃមួយនេះ នឹងផ្តល់នូវអត្ថប្រយោជន៍ ដល់អ្នកអានក្នុងកំរិតណាមួយមិនខាន ហើយជាពិសេសសូមអភ័យទោសទុកជាមុន នូវរាល់កំហុសខុសឆ្គាំឆ្គងដោយអចេតនាដោយប្រការណាមួយ លើសពីនេះទៅទៀត យើងខ្ញុំរង់ចាំស្វាគមន៍ ក្នុងការរិះគុណតិះទៀនក្នុងន័យស្ថាបនា ដើម្បីកែលំអនូវរាល់កំហុសឆ្គង ពីសំណាក់មិត្តអ្នកអាន ដោយក្តីសោមនស្សរីករាយ ដើម្បីឲ្យសារណានេះកាន់តែមានភាពសុក្រឹត និងប្រសើរឡើង។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ០១

## ជំពូកទី១
## សញ្ញាពាណិជ្ជកម្មទូទៅ និង សមត្ថកិច្ចចេញដីការ ក្សាការពារ

**ផ្នែកទី១ សញ្ញាណទូទៅ** ........................................ ០៣

កថាភាគទី១ និយមន័យ ........................................ ០៣

កថាភាគទី២ ប្រវត្តិ ........................................ ០៤

កថាភាគទី៣ វិសាលភាព ........................................ ០៥

កថាភាគទី៤ គោលបំណង ........................................ ០៥

**ផ្នែកទី២ ស្ថាប័នមានសមត្ថកិច្ច** ........................................ ០៦

កថាភាគទី១ អាជ្ញាសាលា ........................................ ០៦

កថាភាគទី២ សាលាដំបូងរាជធានី/ខេត្ត ........................................ ០៧

កថាភាគទី៣ សាលាឧទ្ធរណ៍ ........................................ ០៨

កថាភាគទី៤ តុលាការកំពូល ........................................ ០៨

កថាភាគទី៥ តុលាការមានសមត្ថកិច្ចលើអង្គសេចក្តី ........................................ ០៨

កថាភាគទី៦ សាលាដំបូងដែលមានសមត្ថកិច្ចលើវត្ថុដែលត្រូវរឹបអូស ........................................ ០៩

**ផ្នែកទី៣ នីតិវិធីនៃការដាក់ពាក្យសុំរក្សាការពារ** ........................................ ០៩

កថាភាគទី១ របៀបដាក់ពាក្យសុំ ........................................ ០៩

កថាភាគទី២ ការបញ្ជូន ........................................ ០៩

## ជំពូកទី២
## ការចាត់ចែង និងការអនុវត្ត ជាបណ្តោះអាសន្ន

**ផ្នែកទី១ ប្រភេទ ល័ក្ខខ័ណ្ឌ និង នីតិវិធី នៃការចាត់ចែងជាបណ្តោះអាសន្ន** ........................................ ១៤

កថាភាគទី១ ប្រភេទនៃការចាត់ចែងជាបណ្តោះអាសន្ន ........................................ ១៤

កថាភាគទី២ ល័ក្ខខ័ណ្ឌនៃការចាត់ចែងជាបណ្តោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ.. ១៤

កថាភាគទី៣ ល័ក្ខខ័ណ្ឌនៃការចាត់ចែងជាបណ្តោះអាសន្ន ដែលកំណត់ឋានៈ.................... ១៥

កថាភាគទី៤ វិធីនៃការចាត់ចែងជាបណ្តោះអាសន្ន ........................................ ១៧

**ផ្នែកទី២ ដីកាសម្រេចចាត់ចែងរក្សាការពារជាបណ្ដោះអាសន្ន**....................១៩
កថាភាគទី១ បញ្ញត្តិដែលអនុវត្តដូចគ្នាជាមួយនឹងការរឹបអូសជាបណ្ដោះអាសន្ន....................១៩
កថាភាគទី២ តុលាការមានសមត្ថកិច្ច....................១៩
កថាភាគទី៣ វិធីនៃការវិនិច្ឆ័យ....................១៩
កថាភាគទី៤ ដីកាសម្រេច....................២០
**ផ្នែកទី៣ ការតវ៉ាចំពោះការចាត់ចែង និង ការអនុវត្តជាបណ្ដោះអាសន្ន**....................២០
**កថាភាគទី១ ឧបាស្រ័យចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន**....................២០
១. បញ្ញត្តិដែលអនុវត្តដូចគ្នាជាមួយនឹងការរឹបអូសជាបណ្ដោះអាសន្ន....................២០
២. អានុភាពនៃការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន....................២០
៣. ការលុបចោលការចាត់ចែងជាបណ្ដោះអាសន្នដោយស្ថាពរ....................២១
**កថាភាគទី២ ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន**....................២៣
១. បញ្ញត្តិដែលអនុវត្តដូចគ្នាជាមួយនឹងការរឹបអូសជាបណ្ដោះអាសន្ន....................២៣
២. វិធីនៃការអនុវត្ត....................២៣
៣. អានុភាពនៃការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន....................២៤

## ជំពូកទី៣
## ការរឹបអូស និង ការអនុវត្តជាបណ្ដោះអាសន្ន

**ផ្នែកទី១ លក្ខខណ្ឌនៃការរឹបអូសជាបណ្ដោះអាសន្ន**....................២៧
កថាភាគទី១ លក្ខខណ្ឌលើសិទ្ធិដែលត្រូវការពារ....................២៧
កថាភាគទី២ ភាពចាំបាច់នៃការរក្សាការពារ....................២៧
**ផ្នែកទី២ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**....................២៨
កថាភាគទី១ តុលាការនៃការរឹបអូសជាបណ្ដោះអាសន្ន....................២៩
កថាភាគទី២ ពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន....................២៩
កថាភាគទី៣ វិធីនៃការវិនិច្ឆ័យ....................៣០
កថាភាគ៤ ដីកាសម្រេច....................៣១
**ផ្នែកទី៣ ឧបាស្រ័យចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**....................៣២
កថាភាគទី១ ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន....................៣២
កថាភាគទី២ ការលុចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន....................៣៤
កថាភាគទី៣ បណ្ដឹងជំទាស់....................៣៦

**ផ្នែកទី៤ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន**...................................................................................៣៧
កថាភាគទី១ ល័ក្ខខ័ណ្ឌនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន.............................................៣៧
កថាភាគទី២ ប្រភេទផ្សេងៗ នៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន......................................៣៨
កថាភាគទី៣ ការផ្អាក និងការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន........................៤០
កថាភាគទី៤ ការបំលែងពីការរឹបអូសបណ្តោះអាសន្ន ទៅជាការអនុវត្តដោយបង្ខំ..................៤០
**សេចក្តីសន្និដ្ឋាន និង អនុសាសន៍**.............................................................................................................៤២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

នៅក្នុងសង្គមសេដ្ឋកិច្ចទីផ្សារសេរី បុគ្គលម្នាក់ៗចូលរួមយ៉ាងសកម្មក្នុងជីវភាពសេដ្ឋកិច្ចសង្គម តាមរយៈការដោះដូរទំនិញ និង សេវាដោយប្រើរូបិយវត្ថុជាចម្បង។ ហើយរឿងទាំងអស់នេះគឺធ្វើឡើង តាមរយៈកិច្ចសន្យា ឬ ការសន្យារបស់បុគ្គលម្នាក់ៗ ដែលធ្វើឡើងតាមទំនៀមទំលាប់នៃទីកន្លែង ឬតាម ការចុះកិច្ចសន្យារវាងគ្នានិងគ្នាតាមពេលបច្ចុប្បន្ននេះផងដែរ។ ទន្ទឹមនឹងនោះដែរក៏ធនាគារ ឬ រូបវន្ត បុគ្គលមួយចំនួនបង្កើតឲ្យមានការខ្ចីប្រាក់ ក្នុងការធ្វើដើមទុករកស៊ី ឬ ធ្វើជំនួញជួញដូរ។ ដូច្នេះហើយ រាល់ទំនងទាំងអស់នេះក្នុងសង្គម តែងតែមានករណីខ្លះ ដែលមានវិវាទកើតឡើងរវាងកូនបំណុល ជាមួយម្ចាស់បំណុល។ ចុះចំពោះការដោះស្រាយវិញយ៉ាងណា? ការដោះស្រាយ គឺត្រូវប្ដឹងទៅ តុលាការដើម្បីជួយដោះស្រាយស្វែងរកយុត្តិធម៌ និង ទាមទារនូវសំណង ឬ ការចូលរួមជួយអន្តរាគមន៍ ដើម្បីយកវត្ថុអ្វីមួយ(កម្មវត្ថុនៃវិវាទ)ជាដើម។ ដើម្បីរក្សានូវកម្មវត្ថុនៃវិវាទនៃកិច្ចសន្យា ឬដើម្បីការពារទប់ ស្កាត់នូវវត្ថុអ្វីមួយ ដែលមានតម្លៃក្នុងការសងបំណុលទាំងនោះ ក៏ជាផ្នែកមួយក្នុងការការពារសណ្ដាប់ ធ្នាប់ និងភយន្តរាយទាំងឡាយណាដែលភាគីយល់ថាចាំបាច់ ដោយវិធានការទាំងឡាយនោះ ត្រូវបាន គាំទ្រពីច្បាប់របស់ប្រទេស ជាក់ស្ដែងមានបង្កើតជាច្បាប់នៃ "**ការចាត់ចែងរក្សាការពារ និង ការរឹបអូសជាបណ្ដោះអាសន្ន**" ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដែលជាយន្តការណ៍ពិសេសមួយសម្រាប់ការពារ នូវអំពើទាំងឡាយណាដែលភាគីយល់ថា មានការលំបាក ឬជាតម្រូវការ ដោយរៀបចំទុកទប់ស្កាត់ ឬ រារាំងនូវសកម្មភាពទាំងនោះជាមុន។ ក្នុងន័យនេះដែរ គឺការពារនូវករណីកូនបំណុលមិនមានប្រាក់សង តាមកិច្ចសន្យានោះក្នុងការទាញយកផលប្រយោជន៍របស់ម្ចាស់បំណុល។ ចំពោះករណី បើកូនបំណុល មានអចលនវត្ថុដែលអាចដាក់ការរក្សាការពារ ឬ ការរឹបអូសលើអចលនវត្ថុនោះ ដើម្បីជាការប្រយ័ត្នទៅ ថ្ងៃអនាគត់ ដោយខ្លាចថាកូនបំណុលមិនមានលទ្ធភាពអាចសងបាន។ ក្នុងគោលបំណងនេះគឺដើម្បីទប់ ស្កាត់ការលក់ ឬ ការផ្ទេរអចលនវត្ថុនោះទៅឲ្យអ្នកផ្សេងដើម្បីគេចពីការសងដល់ម្ចាស់បំណុល តាមរ យៈច្បាប់នេះ។

អាស្រ័យហេតុនេះហើយ ទើប **ព្រះរាជាណាចក្រកម្ពុជា** យើងបានបង្កើតច្បាប់ជាច្រើនដើម្បី ការពារនូវផលប្រយោជន៍ជូនដល់ប្រជាពលរដ្ឋ ជាក់ស្ដែងនៅក្នុង **នីតិកាលទី ៣ នៃរដ្ឋសភា** ក្នុងនាម ជាសេនាធិការរបស់រាជរដ្ឋាភិបាលលើវិស័យយុត្តិធម៌ **ក្រសួងយុត្តិធម៌** បានសម្រេចនូវសមិទ្ធិផល របស់ខ្លួណ ក្នុងវិស័យនីតិកម្ម។ សក្ខីភាពនេះ គឺ "**ក្រមនីតិវិធីរដ្ឋប្បវេណី**" ដែលត្រូវបានដាក់ឲ្យអនុ វត្តនៅទូទាំងប្រទេសចាប់តាំងពីខែកក្កដា ឆ្នាំ២០០៧ ព្រមជាមួយអត្ថិភាពនៃ "**ក្រមរដ្ឋប្បវេណី**" ដែលត្រូវបានប្រកាសឲ្យប្រើដោយ **ព្រះមហាក្សត្រ** នាថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលក្រម ទាំងពីរនេះ

ជាកិច្ចសហប្រតិបត្តិការ រវាងអង្គការ JICA និង **ក្រសួងយុត្តធម៌**។ សមិទ្ធិផលជាទីមោទនៈនេះជាចំណែកដ៏សំខាន់មួយក្នុងការចូលរួមអនុវត្តនូវគោលនយោបាយ កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការនៅកម្ពុជា។

ដោយសារតែការចាត់ចែងរក្សាការពារ គឺជានីតិវិធីមួយដែលថ្មី ហើយមានបញ្ញត្តិនៅក្នុងគន្ថីទី ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដូច្នោះយើងត្រូវដឹងជាមុនថា តើសញ្ញាណទូទៅ និង សមត្ថកិច្ចចេញដីការជាស្ថាប័នណាខ្លះ? តើអ្វីទៅជាការចាត់ចែងរក្សាការពារ មានប្រភេទ ល័ក្ខខ័ណ្ឌ និង នីតិវិធីអ្វីខ្លះ? តើអ្វីទៅជាការរឹបអូសជាបណ្តោះអាសន្ន មានល័ក្ខខ័ណ្ឌ និង នីតិវិធីអ្វីខ្លះ?

ការស្រាវជ្រាវប្រធានបទខាងលើមានគោលបំណង ដើម្បីឲ្យមានការរីកចម្រើនដល់វិស័យច្បាប់ ហើយក្នុងនោះដែរគឺផ្តោតសំខាន់លើលក្ខណៈទូទៅសមត្ថកិច្ចចេញដីកាប្រភេទនៃដីការ ល័ក្ខខ័ណ្ឌនិងនីតិវិធី នៃការចាត់ចែងរក្សាការពារជាបណ្តោះអាសន្ន និង ការរឹបអូសជាបណ្តោះអាសន្ន។

ក្នុងនេះដែរប្រសិទ្ធិភាពនៃការដែនសមត្ថកិច្ច ក្នុងការអនុវត្តការចាត់ចែងរក្សាការពារ និង ការរឹបអូសជាបណ្តោះអាសន្ន នៃប្រធានបទគឺសំដៅទៅលើ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦ ត្រង់គន្ថីទី៦ និង គន្ថីទី៧។

ចំពោះប្រធានបទខាងលើ មានអត្ថប្រយោជន៍ដល់អ្នកអានមានការយល់ឲ្យបានស៊ីជម្រៅនិងឲ្យច្បាស់អំពី ការចាត់ចែងរក្សាការពារ និង ការរឹបអូស ដើម្បីការពារផលប្រយោជន៍របស់ខ្លួនអំពីកូនបំណុល ហើយម្យ៉ាងវិញទៀតក៏អាចយល់ដឹងឲ្យច្បាស់អំពីនីតិវិធី និង ល័ក្ខខ័ណ្ឌទាំងនេះផងដែរ។

ក្នុងការសិក្សានៃការចាត់ចែងរក្សាការពារ និង ការរឹបអូសនេះឲ្យបានស៊ីជម្រៅនោះ តើយើងត្រូវសិក្សាអំពីអ្វីខ្លះ? ក្នុងការសិក្សានេះផងដែរ គឺបែងចែកចេញជាបីជំពូកគឺ ៖

**ជំពូកទី១** ៖ សញ្ញាណទូទៅ និងសមត្ថកិច្ចចេញដីការរក្សាការពារ ដែលចែកចេញជាបីផ្នែកទៀតគឺ ផ្នែកទី១សញ្ញាណទូទៅ ផ្នែកទី២ស្ថាប័នមានសមត្ថកិច្ច និង ផ្នែកទី៣នីតិវិធីនៃកាដាក់ពាក្យសុំ

**ជំពូកទី២** ៖ ការចាត់ចែង និង ការអនុវត្ត ជាបណ្តោះអាសន្ន ចែកចេញជាបីផ្នែកដែរគឺ ផ្នែកទី១ ប្រភេទ ល័ក្ខខ័ណ្ឌ និង នីតិវិធី នៃការចាត់ចែងជាបណ្តោះអាសន្ន ផ្នែកទី២ ដីការសម្រេចចាត់ចែងរក្សាការពារជាបណ្តោះអាសន្ន និង ផ្នែកទី៣ ការតវ៉ាចំពោះការចាត់ចែងនិងការអនុវត្តជាបណ្តោះអាសន្ន

**ជំពូកទី៣** ៖ ការរឹបអូស និងការអនុវត្តជាបណ្តោះអាសន្ន ចែកជាបួនផ្នែក គឺផ្នែកទី១ ល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្តោះអាសន្ន ផ្នែកទី២ ដីការសម្រេចរឹបអូសជាបណ្តោះអាសន្ន ផ្នែកទី៣ ឧបាស្រ័យចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និងផ្នែកទី៤ ការអនុវត្តជាបណ្តោះអាសន្ន។

ចំណុចទាំងអស់នេះយើង និង សិក្សាជាមួយគ្នាបន្តបន្ទាប់ទៀត ដើម្បីយល់ដឹងឲ្យរឹតតែច្បាប់ទៅលើប្រធានបទនេះ។

# ជំពូកទី១

# សញ្ញាណទូទៅ និងសមត្ថកិច្ចចេញដីការ រក្សាការពារ

ដោយសារតែសង្គមនាពេលបច្ចុប្បន្ននេះ មានការរីកចម្រើនយ៉ាងឆាប់រហ័ស ពីមួយថ្ងៃទៅមួយថ្ងៃ ហើយចំពោះការទំនាក់ទំនងគ្នាមានរឹតតែច្រើនក្នុងការប្រកបរបរចិញ្ចឹមជីវិត។ ឆ្លងតាមទំនាក់ទំនងនេះបានបង្កើតឡើងនូវសិទ្ធិ និង កាតព្វកិច្ចរវាងកូនបំណុល និង ម្ចាស់បំណុល។ ក្នុងនោះដែរដោយសារតែម្ចាស់បំណុល មានការព្រួយបារម្ភថាកូនបំណុលរបស់ខ្លួន មិនអាចអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនបាននាពេលអនាគត ទើបបានជានៅក្នុង **ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦** បានបញ្ញត្តិនៅត្រង់ **គន្ថីទី៧ ស្តីពីការចាត់ចែងរក្សាការពារ**។ តាមរយៈគន្ថីនេះមានការលើកឡើងជាសំណួរផងដែរថា ៖

- តើសញ្ញាណក្នុងការចាត់ចែងរក្សាការពារជាអ្វី?
- ហើយតើស្ថាប័នណាខ្លះដែលមានសមត្ថកិច្ចចេញដីការ?

## ផ្នែកទី១ សញ្ញាណទូទៅ

ការចាត់ចែងរក្សាការពារ គឺជាវិធានការដ៏ចម្បងមួយដើម្បីការពារសិទ្ធិ និង ផលប្រយោជន៍របស់ម្ចាស់បំណុល ឬ អ្នកមានផលប្រយោជន៍ផ្សេងទៀត ក្នុងការប្រើសិទ្ធិទាមទារបំណុលរបស់ខ្លួនដោយយកសាលក្រម ឬសាលដីកា ពីតុលាការទៅអនុវត្តដោយបង្ខំទៅលើកូនបំណុលរបស់ខ្លួន ឬអ្នកដែលជាប់ពាក់ព័ន្ធ។

តើខ្លឹមសារនៃការចាត់ចែងរក្សាការពារមានអត្ថន័យយ៉ាងណា?

### កថាភាគទី១ និយមន័យ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងការពារ និង ថែរក្សាស្ថានភាពបច្ចុប្បន្នដោយប្រើអំណាចរបស់រដ្ឋ ដើម្បីការពារសិទ្ធរបស់បុគ្គលណាម្នាក់ នៅពេលដែលមានការបារម្ភថា ដោយខ្លាចមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ន នៃទ្រព្យសម្បត្តិរបស់កូនបំណុលក្នុងការអនុវត្តឬមានការបារម្ភថាមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារតែមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិក្នុងគោលបំណងចង់ការពារសិទ្ធរបស់ខ្លួន[១]។

ចំពោះការចាត់ចែងរក្សាការពារ ចែកចេញជាពីរប្រភេទគឺ ការរឹបអូសជាបណ្តោះអាសន្ន និង ការចាត់ចែងរក្សាការពារជាបណ្តោះអាសន្ន។

[១] មាត្រា ៥៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ។

**កថាភាគទី២ ប្រវត្តិ**

ការចាត់ចែងរក្សាការពារតាមនីតិវិធីចាស់ មិនត្រូវបានកំណត់នៅក្នុងច្បាប់ទេ តែត្រូវបានបង្កើតតាមការអនុវត្តជាក់ស្តែង ចេញពីកថាខណ្ឌស្តីពី "វិធានការបណ្តោះអាសន្ន" នៃសារាចរលេខ ០៤ សរចន ៨៤ ឆ្នាំ ១៩៨៤ របស់ក្រសួងយុត្តិធម៌ ។ ប៉ុន្តែខ្លឹមសារ និង នីតិវិធីនៃ "វិធានការបណ្តោះអាសន្ន" ដែលមានចែងនៅក្នុងកថាខណ្ឌ នោះមិនមានភាពច្បាស់លាស់ទេ។ ដោយសារនៅក្នុង "វិធានការបណ្តោះអាសន្ន" ក្នុងរឿងរដ្ឋប្បវេណី រួមមាន ៖

- ដីកាសម្រេចតាមពាក្យសុំ[២]
- ដីការសម្រេចកិច្ចការប្រញាប់[៣]
- ដីកាបំបែកលំនៅដ្ឋាន (ក្នុងរឿងអាពាហ៍ពិពាហ៍) ជាដើម ។

ចៅក្រមពេលទទួលពាក្យបណ្តឹង រហូតដល់ពេលជំនុំជម្រះ ចៅក្រមមានសិទ្ធិចេញដីកាសម្រេចជាប្រញាប់ តាមសំណូមពររបស់គូភាគី ប្រសិនបើយល់ថាជាចាំបាច់។ ដីកាសម្រេចនេះមានគោលដៅការពារការអន្តរាយផ្សេងៗ ដែលអាចកើតមានជាយថាហេតុ ដូចជាដីកាសម្រេចឲ្យប្តី និង ប្រពន្ធដែលសុំលែងលះគ្នា បែកលំនៅពីគ្នាជាបណ្តោះអាសន្ន។ ដីកាសម្រេចកត់ត្រាទ្រព្យសម្បត្តិ និង ប្រគល់សិទ្ធិដល់ជនណាម្នាក់ ឲ្យថែរក្សាជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិ ដែលមានទំនាស់ដើម្បីការពារផលប្រយោជន៍របស់គូភាគី[៤] ។

ដោយនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ នៅត្រង់គន្ថីទី៧ បានចែងនូវបទប្បញ្ញត្តិលំអិតស្តីពីការចាត់ចែងរក្សាការពារ ដោយឈរលើគោលគំនិតនៃភាពច្បាស់លាស់នៃនីតិវិធី និង ខ្លឹមសារនៃការចាត់ចែងរក្សាការពារ ជាការអនុវត្តដ៏សមរម្យមួយ ដែលត្រូវយកបញ្ញត្តិ នៃក្រមនីតិវិធីរដ្ឋប្បវេណីទៅអនុវត្ត[៥]។ ប៉ុន្តែនីតិវិធីនៃការចាត់ចែងរក្សាការពារ គឺជានីតិវិធីមួយដ៏ស្មុគស្មាញដែលរួមបញ្ចូលទាំងនីតិវិធីនៃការសម្រេចសេចក្តីផង និងនីតិវិធីនៃការអនុវត្តចាស់(វិធានការបណ្តោះអាសន្ន) នៃសារាចរលេខ ០៤

[២] ពាក្យពីដើមហៅថា (ដីកាចារលើពាក្យ) ជាប្រភេទសេចក្តីសម្រេចមួយមុនអង្គសេចក្តី គូភាគីអាចស្នើសុំទៅតុលាការ បានគ្រប់ពេលវេលា ដើម្បីឲ្យតុលាការចេញសេចក្តីសម្រេចតាមពាក្យសុំនេះ (ទំព័រ២៧នៃអត្ថាធិប្បាយ ច្បាប់ភាគ៣ ក្នុងរឿងរដ្ឋប្បវេណីរបស់ លោក ហ៊ីង ធីឫទ្ធី បោះពុម្ពឆ្នាំ ២០០៧) ។

[៣] ជាប្រភេទដីកា ទប់ស្កាត់ការ ការពារដូចដីការសម្រេចតាមពាក្យស្នើសុំដែរ គ្រាន់តែដីកាប្រញាប់នេះតុលាការកោះហៅ គូភាគីទាំងពីរមកសាកសួរ(ទំព័រ៣១នៃអត្ថាធិប្បាយ ច្បាប់ភាគ៣ ក្នុងរឿងរដ្ឋប្បវេណីរបស់លោក ហ៊ីង ធីឫទ្ធី បោះពុម្ពឆ្នាំ២០០៧)។

[៤] ទំព័រ ២២ នៃអត្ថាធិប្បាយច្បាប់ភាគ៣ ក្នុងរឿងរដ្ឋប្បវេណីរបស់ លោក ហ៊ីង ធីឫទ្ធី បោះពុម្ពឆ្នាំ២០០៧ ។

[៥] ទំព័រ ២២៣ នៃសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី(ភាគ២) ។

សរច ៨៤ ឆ្នាំ១៩៨៤ របស់ក្រសួងយុត្តិធម៌ ដែលមានភាពមិនច្បាស់លាស់ ដោយឈរលើគោលគំនិត បង្ហាញពីភាពច្បាស់លាស់នៃនីតិវិធី និងខ្លឹមសារនៃការចាត់ចែងរក្សាការពារ។

**កថាភាគទី៣ វិសាលភាព**

ការចាត់ចែងរក្សាការពារមានវិសាភាពធំទូលាយ ហើយការអនុវត្តរបស់វាមានការទាក់ទងដល់ការរឹបអូសជាបណ្ដោះអាសន្ន និងការចាត់ចែងជាបណ្ដោះអាសន្ន។ ការអនុវត្តការចាត់ចែងរក្សាការពារនេះបានលុះត្រាតែមានដីកាដែលចេញដោយតុលាការមានសមត្ថកិច្ច។ ការអនុវត្តនេះមានលក្ខណៈធំទូលាយ ដោយធ្វើយ៉ាងណាដើម្បីការពារនូវភាពស្របច្បាប់របស់ដើមបណ្ដឹង។ ដែនអនុវត្ត របស់ការចាត់ចែងរក្សាការពារ ត្រូវរួមបញ្ចូលផងដែរ នូវបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល និង នីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។

**កថាភាគទី៤ គោលបំណង**

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងដើម្បីការពារសិទ្ធិ និង ផលប្រយោជន៍របស់ម្ចាស់បំណុល ក្នុងការប្រើសិទ្ធិទាមទារបំណុល ដោយយកលិខិតអនុវត្តពីតុលាការទៅអនុវត្តដោយបង្ខំលើកូនបំណុលរបស់ខ្លួន។ ទោះបីជាការចាប់ផ្ដើមអនុវត្តដោយបង្ខំតម្រូវឲ្យបំពេញនូវល័ក្ខខ័ណ្ឌ ដូចជាអត្ថិភាពនៃលិខិតអនុវត្ត និង ការមកដល់នៃពេលកំណត់សងក៏ដោយ ក៏ត្រូវតែទប់ស្កាត់ជាមុនដោយមិនឲ្យមានការប្រែប្រួលផ្លូវច្បាប់ និង ស្ថានភាពជាក់ស្ដែងក្នុងគោលដៅធានាដល់ការអនុវត្តដោយបង្ខំនាពេលអនាគត។

ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើលិខិតបញ្ជាក់កាតព្វកិច្ច ដូចជាសាលក្រមស្ថាពរជាដើម ហេតុនេះហើយដើម្បីឲ្យបានសាលក្រមនេះ ត្រូវដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណី ថែមទាំងត្រូវការពេលវេលាច្រើន។ ក៏ប៉ុន្តែមុនពេលទទួលសាលក្រមនេះ កូនបំណុលនៃការអនុវត្តអាច លក់ ឬផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនដែលជាហេតុមិនអាចធ្វើ ឬ ធ្វើឲ្យមានការលំបាក ដល់ធ្វើការអនុវត្តដោយបង្ខំនៅពេលក្រោយបាន ឬមួយក៏ភាគីណាមួយអាចទទួលការខូចខាតធ្ងន់ធ្ងរ ឬទទួលគ្រោះថ្នាក់ដល់ឋានៈរបស់ខ្លួន ដោយសារវិវាទពាក់ព័ន្ធនឹងទំនាក់ទំនងនៃសិទ្ធិរវាងភាគីទាំងសងខាង។ ក្នុងករណីនេះបុគ្គលដែលចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារឲ្យមានការចាត់ចែងរក្សាការពារ[៦]។ ការចាត់ចែងរក្សាការពាររួមមានការរឹបអូសជាបណ្ដោះអាសន្ន និង ការចាត់ចែងជាបណ្ដោះអាសន្ន។

[៦] ទំព័រទី ៥២៥ ក្នុងចំណុច(២) នៃសេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ផ្នែកទី២ ស្ថាប័នសមត្ថកិច្ច

បណ្តឹងរដ្ឋប្បវេណី ភាគីគឺជាម្ចាស់បណ្តឹង ដូច្នេះការកំណត់សមត្ថកិច្ចតុលាការជារឿងសំខាន់ណាស់ ដោយសារថានៅពេលដាក់ពាក្យសុំទៅតុលាការ កាលណាពាក្យសុំខុសពីសមត្ថកិច្ចរបស់តុលាការ នោះពាក្យសុំនោះនឹងត្រូវបានលើកចោលដោយតុលាការនោះ។ នៅក្នុងន័យនេះតុលាការមិនចាត់ការទៅតាមការទាមទាររបស់អ្នកដាក់ពាក្យសុំឡើយ។ សមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូង ដែលមានសមត្ថកិច្ចលើទីកន្លែងវត្ថុ ដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ[៧]។ នៅក្នុងនីតិវិធីនៃការចាត់ចែង បណ្តឹងរដ្ឋប្បវេណីមានគោលបំណងសុំឲ្យតុលាការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី ដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។ បណ្តឹងរដ្ឋប្បវេណី គឺជាបណ្តឹងដែលម្ចាស់បំណុលដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។ តុលាការតាមរយៈអត្ថន័យនេះ ដោយផ្អែកទៅលើ មាត្រា១២៨ វាក្យខណ្ឌទី៤ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា បានចែងថាអំណាចនេះត្រូវប្រគល់ឲ្យ តុលាការកំពូល និង តុលាការគ្រប់ជាន់ថ្នាក់។

### កថាភាគទី១ អាជ្ញាសាលា

អាជ្ញាសាលា គឺជាស្ថាប័នតុលាការដាច់ដោយឡែកមួយ ដែលទទួលបន្ទុកក្នុងការអនុវត្តដោយបង្ខំ និងការងារពាក់ព័ន្ធ ហើយដោយមានមន្ត្រីរាជការដែលមានឈ្មោះថាអាជ្ញាសាលា។ អាជ្ញាសាលាគឺជាស្ថាប័នយុត្តាធិការឯករាជ្យមួយស្ថិតនៅក្រោមក្រសួងយុត្តិធម៌ ដែលទទួលបន្ទុកធ្វើការបញ្ជូនឯកសារនានា ដែលចេញដោយតុលាការ[៨]។ អាជ្ញាសាលា មិនមែនជាស្ថាប័នជំនួយបន្ថែមរបស់តុលាការអនុវត្តទេ[៩]។ ច្បាប់អនុញ្ញាតឲ្យតុលាការ អនុវត្តផ្តល់ការណែនាំប្រគល់សិទ្ធិ និង បង្គាប់អាជ្ញាសាលានៅក្នុងករណីជាក់លាក់ ដូចជា(ការអនុវត្តថ្ងៃសម្រាក ឬ ពេលយប់) ដោយអាជ្ញាសាលា ត្រូវបង្ហាញលិខិតបញ្ជាក់ថាខ្លួនបានទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ ឬ តុលាការ អនុវត្តស្ថិតនៅ ឬ តុលាការអនុវត្តដែលចេញសេចក្តីបង្គាប់[១០]។ ដោយបញ្ញត្តិទាំងនេះត្រូវបានរៀបចំឡើង ដោយយកទំនាក់ទំនងឯករាជ្យរវាងស្ថាប័នទាំងពីរមកជាមូលដ្ឋាន ដោយគិតពិចារណាអំពីចរិត លក្ខណៈរបស់

[៧] មាត្រា ៥៤០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៨] មាត្រា ២៤៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

[៩] នៃសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ២ ទំព័រ១៧ ចំណុច៣(៣)។

[១០] មាត្រា៣៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

ស្ថាប័ននីមួយៗផងដែរ។ ចំពោះរដ្ឋបាលយុត្តាធិការវិញ អាជ្ញាសាលាត្រូវទទួលការត្រួតពិនិត្យ ពីសាលាដំបូងដែលខ្លួនស្ថិតនៅចំពោះមុខងាររបស់ខ្លួន។

នីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលអាជ្ញាសាលាទទួលបន្ទុកដោយឯករាជ្យក្នុងនាមជាស្ថាប័នអនុវត្តរួមមាន ៖

- ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ។
- ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ។
- ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ។
- ការអនុវត្តដោយបង្ខំឲ្យប្រគល់ចលនវត្ថុ។

ក្នុងនាមជាស្ថាប័នអនុវត្ត អាជ្ញាសាលាមានសិទ្ធិអំណាចបន្ទាប់បន្សំលើចំនុចដូចជាការថែរក្សាគ្រប់គ្រងអចលនវត្ថុ ដែលជាកម្មវត្ថុក្នុងការអនុវត្តការលក់ ការដកហូតលិខិតបញ្ជាក់សញ្ញាតិនាវាជាដើម។

**កថាភាគទី២ សាលាដំបូងរាជធានី/ខេត្ត**

តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការ ដែលអាចទទួលពាក្យបណ្ដឹងដោយស្របច្បាប់ និងវិនិច្ឆ័យរឿងក្ដី ហើយចេញសាលក្រម ឬសាលដីកាបាន[១១]។ តុលាការដែលត្រូវអនុវត្ត ការចាត់ចែងរក្សាការពារត្រូវហៅថា តុលាការអនុវត្ត ការចាត់ចែងរក្សាការពារ[១២] ហើយសមត្ថកិច្ចនេះអាចកំណត់បានទៅលើ លំនៅដ្ឋានរបស់ចុងចម្លើយ ឬ កំណត់ទៅតាមទ្រព្យសម្បត្តិដែលតាំងនៅ[១៣]។ សាលាដំបូងរាជធានី ខេត្ត គឺជាអាជ្ញាធរដែលមានសមត្ថកិច្ចរបស់សាលាក្ដីដែលមានតួនាទី ទទួលជំនុំជំរះរឿងវិវាទដែលគូភាគីប្ដឹង ឬ ក៏សមត្ថកិច្ចសាលាណាមួយដែលមានតួនាទីកាត់ក្ដី ហើយសាលក្រមរបស់សាលានោះ ត្រូវច្បាប់អោយអនុវត្ត។ សាលាជម្រះក្ដីដែលទទួលពាក្យបណ្ដឹងខុសពីសមត្ថកិច្ចរបស់ខ្លួន ត្រូវតែប្រកាសថាខ្លួនគ្មានសមត្ថភាព ហើយប្រាប់គូភាគី អោយទៅរកសាលាដែលមានសមត្ថភាព ក្នុងរឿងវិវាទរបស់គូភាគីនោះ[១៤]។ នោះមានន័យថា ច្បាប់ហាមឃាត់ចៅក្រម មិនឲ្យទូន្មានភាគីឡើយ ដោយទុកឲ្យមេធាវី ជាអ្នកចង្អុលបង្ហាញ នូវសាលាមានសមត្ថកិច្ច ទៅភាគីជំនួសវិញ។ ក្នុងករណីដែលតុលាការ

[១១] មាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[១២] មាត្រា ៥៣២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[១៣] មាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[១៤] ទំព័រ ២៩ នៃកម្រងច្បាប់ខ្មែរ ក្រមរបៀបក្ដីផ្នែករដ្ឋប្បវេណី រៀបរៀងដោយសាស្ត្រាចារ្យបណ្ឌិត ស សូវាន ។

អនុវត្ត ដើរតួនាទីជាស្ថាប័នអនុវត្តដោយផ្ទាល់ ប្រភេទនៃនីតិវិធីអនុវត្តដែលស្ថិតនៅក្រោមសមត្ថកិច្ចតុលាការនេះរួមមាន៖

« ការអនុវត្តដោយបង្ខំ

« ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និងទ្រព្យសម្បត្តិផ្សេងៗទៀត លើអចលវត្ថុ

« ការអនុវត្តដោយបង្ខំអោយប្រគល់វត្ថុក្នុងករណីដែលវត្ថុត្រូវបានកាន់កាប់ដោយ តតិយជន

« ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ច ដែលមានគោលបំណងអោយធ្វើ ឬមិនធ្វើសកម្មភាពណាមួយ។

**កថាភាគទី៣ សាលាឧទ្ធរណ៍**

សាលាឧទ្ធរណ៍ ក៏ជាតុលាការដែលមានសមត្ថកិច្ច ក្នុងការចាត់ចែងរក្សាការពារបានផងដែរ ក្នុងករណីដែលអង្គសេចក្តី ត្រូវបានចាត់ការក្នុងនីតិវិធីបណ្តឹងឧទ្ធរណ៍។ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍។ ក្នុងន័យនេះ គឺថា ម្ចាស់បំណុលនៅតំណាក់កាលដំបូង នៅសាលាដំបូងមិនបានដាក់ពាក្យប្តឹងអំពីវត្ថុដែលខ្លួនទាមទារនោះទេ ហើយពេលរឿងក្តីនោះមកដល់សាលាឧទ្ធរណ៍ បែរជាមានចំណុចមួយទៀត ដែលម្ចាស់បំណុលប្តឹង ឲ្យសាលាឧទ្ធរណ៍សម្រេចសេចក្តី ឬបណ្តឹងអង្គសេចក្តីរឿងក្តីនោះ មិនត្រូវបានតុលាការថ្នាក់ក្រោមសម្រេច។

**កថាភាគទី៤ តុលាការកំពូល**

តុលាការកំពូល គឺជាតុលាការមួយដែលទទួលនូវរាល់ការប្តឹងឧបាស្រ័យ ដែលមិនសុខចិត្តនូវសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍។ ចំពោះការប្តឹងផ្តល់ពីតុលាការឧទ្ធរណ៍ ចំពោះការជំទាស់របស់គូភាគីមកតុលាការកំពូល នោះតុលាការកំពូលនឹងសម្រេចសេចក្តីលើពាក្យសុំនោះហើយបិទផ្លូវតវ៉ា។ តែក្នុងករណីនេះចំពោះការប្តឹងសុំឲ្យតុលាការកំពូលចេញសេចក្តីសម្រេចស្តីពីការចាត់ចែងរក្សាការពារ ឬការរឹបអូសជាបណ្តោះអាសន្ននោះ គឺតុលាការកំពូលមិនមានសមត្ថកិច្ចចេញនូវដីកានោះជាដាច់ខាត់។

**កថាភាគទី៥ តុលាការមានសមត្ថកិច្ចលើអង្គសេចក្តី**

អង្គសេចក្តី គឺជារឿងក្តីនៃពាក្យបណ្តឹងដែលពាក្យបណ្តឹងត្រូវបានដាក់ចំពោះសិទ្ធិលើបំណុល ឬដែលត្រូវបានរក្សាការពារទោះបីជាបណ្តឹងអង្គសេចក្តី ដែលមានការពាក់ព័ន្ធនោះ មិនអាចដាក់ទៅតុលាការកម្ពុជាបាន ដូចជាករណីនៃសិទ្ធិទាមទារ ដែលភ្ជាប់ទៅនឹងកិច្ចសន្យាមជ្ឈត្តកម្ម[១៥] ឬ សិទ្ធិទាមទារដែលស្ថិតនៅក្រោមការជម្រះក្តីរបស់តុលាការបរទេស។

[១៥]ជាការព្រមព្រៀងដែលគូភាគី សម្រេចយកវិវាទរបស់ខ្លួនទៅដោះស្រាយតាមផ្លូវមជ្ឈត្តកម្ម ដោយដោះស្រាយវិវាទដោយមជ្ឈត្តករ ទំព័រ៧៧ នៃសន្ទានុក្រមពាក្យច្បាប់របស់ ទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ពលើកទី១ ឆ្នាំ ២០០៧ ។

**កថាភាគទី៦ សាលាដំបូងដែលមានសមត្ថកិច្ចលើវត្ថុដែលត្រូវរឹបអូស**

វត្ថុដែលត្រូវរឹបអូសជាបណ្ដោះអាសន្ន គឺជាវត្ថុក្រៅពីចលនវត្ថុ ដោយត្រូវបញ្ជាក់អំពីវត្ថុដែលជាកម្មវត្ថុនោះទៅក្នុងពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។ បើវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិលើបំណុល ត្រូវចាត់ទុកថាសិទ្ធិលើបំណុលនោះត្រូវស្ថិតនៅ កន្លែងរបស់កូនបំណុល ទី៣ (សមត្ថកិច្ចដែលកំណត់ទៅតាមលំនៅដ្ឋានរបស់បុគ្គល) ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងប្រគល់នាវា ឬ ចលនវត្ថុត្រូវចាត់ទុកថាសិទ្ធិលើបំណុលនោះត្រូវស្ថិតនៅកន្លែងដែលវត្ថុនោះស្ថិតនៅ។

**ផ្នែកទី៣ នីតិវិធីនៃការស្នើសុំរក្សាការពារ**

ការចាត់ចែងរក្សាការពារ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ចំពោះការធានាក្នុងការអនុវត្តដោយបង្ខំនាពេលអនាគតរបស់កូនបំណុល។ ហេតុនេះហើយ ក្នុងនាមយើងចង់ឲ្យតុលាការចេញដីកាចាត់ចែងរក្សាការពារ ត្រូវធ្វើដូចម្ដេចខ្លះ?

គោលការណ៍ក្នុងរឿងរដ្ឋប្បវេណី ភាគីត្រូវដាក់ពាក្យស្នើសុំ ទើបតុលាការសម្រេចដោយឆន្ទានុសិទ្ធិ ហើយក្នុងការអនុវត្តទៀតសោត លុះត្រាតែមានការបញ្ជូន ទៅភាគីឲ្យបានដឹងជាមុន ។

**កថាភាគទី១ របៀបដាក់ពាក្យសុំ**

ពាក្យសុំនីមួយៗត្រូវគោរពទៅតាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ បើពុំដូច្នោះទេពាក្យសុំនោះត្រូវបដិសេធដោយតុលាការដែលមានសមត្ថកិច្ច។ ពាក្យសុំត្រូវធ្វើជាលាយល័ក្ខអក្សរ[១៦] ដូចជាពាក្យសុំឲ្យចេញដីការក្សាការពារនេះជាដើម ។

**កថាភាគទី២ ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ និង សេចក្ដីបញ្ជាក់ដំបូង**

ដីកាសម្រេចចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការតាមពាក្យសុំ[១៧] ឬ យើងអាចនិយាយម្យ៉ាងទៀតបានថា តុលាការអាចចេញដីកាសម្រេចរក្សាការពារបាន លុះត្រាតែមានពាក្យសុំរបស់ភាគីណាមួយដែលត្រឹមត្រូវតាមនីតិវិធី។ ខ្លឹមសារនៅក្នុងពាក្យសុំ ត្រូវសរសេរឲ្យបានច្បាស់លាស់នូវចំណុចដូចខាងក្រោម ៖

ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់[១៨] បានសេចក្ដីថាជនដែលទាមទារនូវ សាលក្រម ឬ សាលដីកា នៅក្នុង

---

[១៦] មាត្រា ៥៣៨កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ។

[១៧] មាត្រា ៥៣២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ។

[១៨] មាត្រា ៥៤១ កថាខណ្ឌទី១(ក) នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ។

នាមខ្លួនដើម្បីដោះស្រាយវិវាទ ព្រមទាំងជនដែលត្រូវបានទាមទារឲ្យចង្អុលឈ្មោះនៅក្នុងសាលក្រម ឬ សាលដីកានោះ ក្នុងនាមខ្លួនជាភាគីម្ខាងទៀត។ ភាគីត្រូវបានគេហៅថាដើមចោទ និង ចុងចម្លើយក្នុងករណីជំនុំជម្រះក្តីលើកទី១ ហើយក្នុងការជម្រះក្តី នៃបណ្តឹងឧទ្ធរណ៍ គេហៅថាដើមបណ្តឹងឧទ្ធរណ៍ និង ចុងបណ្តឹងឧទ្ធរណ៍ ហើយភាគីដើមបណ្តឹងសារទុក្ខ និង ចុងបណ្តឹងសារទុក្ខ នៅក្នុងការជំនុំជម្រះនៃបណ្តឹងសារទុក្ខ។ ដោយសារតែភាគី គឺជាប្រធាននៃនីតិវិធីបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងក្នុងគោលបំណងកំណត់ជាស្ថាពរនូវអត្ថិភាព[១៩] ឬ ភាគីនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិកំណត់ណាមួយ ហើយការពារសិទ្ធិរបស់អ្នកដែលមានសិទ្ធិ ។ សមត្ថកិច្ចភាគី គឺជាលក្ខណៈសម្បត្តិទូទៅដែលអាចក្លាយទៅជាភាគីនៃរឿងក្តីរដ្ឋប្បវេណី។ ហើយប្រសិនបើបុគ្គលផ្សេងដែលពាក់ព័ន្ធ ក្នុងនីតិវិធីបណ្តឹង អាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបានឲ្យមានអានុភាព ឬ អាចទទួលនូវសកម្មភាពបណ្តឹងរបស់តុលាការ និង ភាគីម្ខាងទៀត។ ហើយច្បាប់ក៏បានអនុញ្ញាតផងដែរ ចំពោះករណីដែលភាគីពុំមានសមត្ថភាព ក្នុងការធ្វើបណ្តឹងដោយចាត់ទុកថាជនទាំងនោះ (អនីតិជន និង ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ) ពុំមានលក្ខណសម្បត្តិ ធ្វើសកម្មភាពក្នុងការធ្វើបណ្តឹង ហើយឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ធ្វើសកម្មភាពបណ្តឹងជំនួសជននោះ[២០]។ ហើយក្នុងច្បាប់បានកំណត់ អ្នកប្រតិបត្តិនូវសិទ្ធិតំណាងនោះគឺតុលាការអាចជ្រើសរើស អ្នកតំណាងពិសេស[២១] សម្រាប់ជនដែលនឹងក្លាយជាភាគីម្ខាងទៀតបាន ។

ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ក៏ដូចជាអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវតែកំណត់ឲ្យបានច្បាស់លាស់នៅក្នុងពាក្យសុំ ព្រោះបញ្ហាចោទឡើង នៅពេលដែលតុលាការចេញដីការួចហើយ បើមានភាពខុសឆ្គងដោយសារបញ្ហាឈ្មោះ ឬ អាសយដ្ឋាននោះជាហេតុនាំឲ្យមានការលំបាកក្នុងការអនុវត្តដែរ។ ដោយហេតុនេះហើយត្រូវផ្តល់មធ្យោបាយក្នុងការទាក់ទងឲ្យបានគ្រប់គ្រាន់។

ខ្លឹមសារលំអិតនៃដីកាដែលអ្នកដាក់ពាក្យសុំទាមទារ ក្នុងខ្លឹមសារនៃពាក្យបណ្តឹងត្រូវមានភាពច្បាស់លាស់នៃចំណុចទាមទារ និង ភាពច្បាស់លាស់នៃអង្គហេតុ គឺជាប្រការមួយដែលធ្វើឲ្យតុលាការដែលទទួលពាក្យបណ្តឹង ហើយក៏ជាការធ្វើឲ្យភាគីម្ខាងទៀត នៃការទាមទារងាយស្រួលយល់ពីការទាមទារ និង អាចឆ្លើយតបចំពោះការទាមទារនោះ។ ចំពោះខ្លឹមសារនៃដីកាសម្រេចរក្សាការពារ គឺជា

---

[១៩] ភាពមាន ភាពកើតមាន ភាពស្ថិតនៅ ភាពនៃអ្វីៗដែលមាន (ពាក្យអត្ថិភាព ផ្ទុយនឹងពាក្យ នត្ថិភាព) ទំព័រ ៩១ នៃសន្ទានុក្រមពាក្យច្បាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ពលើកទី១ ឆ្នាំ២០០៧ ។

[២០] មាត្រា ៣២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ។

[២១] មាត្រា ៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ បុគ្គលដែលមានបំណងធ្វើសកម្មភាពបណ្តឹងចំពោះបុគ្គលដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង អាចដាក់ពាក្យសុំទៅតុលាការដែលទទួលបណ្តឹងឲ្យជ្រើសរើសព្រះរាជាអាជ្ញាជាអ្នកតំណាង ពិសេសបានគ្រងកំណត់(៣) នៃទំព័រ៣៤ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ការសំខាន់ណាស់ដែលពុំអាចខ្វះបាន លើសពីនេះទៀតត្រូវតែមាន អត្ថន័យច្បាស់លាស់ សម្រាប់បញ្ជាក់ពីប្រភេទនៃដីកាសម្រេចរក្សាការពារណាមួយ ព្រោះថាដីកាសម្រេចរក្សាការពារ ដោយហេតុថាដីកាសម្រេចរក្សាការពារមានបីប្រភេទ ៖

ដីកាសម្រេចរក្សាការពារដើម្បីធ្វើការរឹបអូសជាបណ្ដោះអាសន្ន។

ដីកាសម្រេចរក្សាការពារ ដើម្បីចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ។

ដីកាសម្រេចរក្សាការពារ ដើម្បីចាត់ចែងជាបណ្ដោះអាសន្ន ដែលកំណត់ឋានៈ ជាបណ្ដោះអាសន្ន។

ខ្លឹមសារនៃ ការចាត់ចែងរក្សាការពារ ជាគោលការណ៍ សំដៅដល់កម្មវត្ថុនៃ ការចេញដីកាសម្រេចរក្សាការពារ ដែលអ្នកដាក់ពាក្យសុំត្រូវសរសេរបញ្ជាក់ ឲ្យបានច្បាស់លាស់នៅក្នុងពាក្យសុំរបស់ខ្លួន។

ឧទាហរណ៍ ៖ ម្ចាស់បំណុល បានដាក់ពាក្យសុំដីការក្សាការពារ ចាត់ចែងជាបណ្ដោះអាសន្ន ប៉ុន្តែនៅពេលដែលពិនិត្យពាក្យសុំឃើញថា ជាប្រភេទរឹបអូសជាបណ្ដោះអាសន្នទៅវិញ។ ដូច្នេះជាដំបូង តុលាការគប្បីផ្ដល់ដំបូន្មានឲ្យម្ចាស់បំណុលកែកំហុសដែលមាននៅក្នុងពាក្យសុំ។ ប្រសិនបើម្ចាស់បំណុលមិនកែតម្រូវកំហុសទេ តុលាការតម្រូវបង្គាប់ឲ្យកែតម្រូវកំហុសនៅក្នុង ពាក្យសុំនោះ ។

បើមានការបង្គាប់ឲ្យកែតម្រូវក៏ដោយ ប្រសិនបើម្ចាស់បំណុល មិនកែតម្រូវកំហុសនោះទេ តុលាការត្រូវលើកចោលពាក្យសុំដោយដីកាសម្រេច[២២]។

ឧទាហរណ៍ ៖ នៅក្នុងរឿងក្ដីនៃការរឹបអូសជាបណ្ដោះអាសន្ន ចំពោះអចលវត្ថុត្រូវកំណត់ឲ្យបានជាក់លាក់នូវកម្មវត្ថុ ដែលត្រូវបានរឹបអូស ហើយទីតាំងដែលអចលវត្ថុនោះស្ថិតនៅ ហើយត្រូវកំណត់ឲ្យបានជាក់លាក់លើសិទ្ធិលើបំណុលដែលត្រូវរក្សាការពារ ដោយសរសេរនៅក្នុងពាក្យសុំឲ្យបានច្បាស់លាស់ ដើម្បីងាយស្រួលដល់តុលាការ ក៏ដូចជាងាយស្រួលក្នុងការកំណត់អំពីសមត្ថកិច្ចដែរ។ ហើយក្នុងករណី ដែលកម្មវត្ថុនោះគឺជាចលនវត្ថុមិនចាំបាច់កំណត់ជាក់លាក់អំពីចលនវត្ថុនីមួយៗទេ តែត្រូវបញ្ជាក់ពីទីកន្លែងដែលចលនវត្ថុនោះស្ថិតនៅ[២៣]។

សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ ត្រូវលើកឡើងតាមរយៈ ការសរសេរឲ្យបានច្បាស់លាស់ និង ត្រូវសរសេរនូវភស្តុតាង តាមហេតុនីមួយៗដោយបញ្ជាក់ និង កំណត់ពីសិទ្ធិ និង ទំនាក់ទំនងគតិយុត្តនោះ ដោយបង្ហាញឲ្យឃើញពីទំនាក់ទំនងជាមួយវត្ថុ ដែលជាកម្មវត្ថុនៃការទាមទារ និង អង្គហេតុសំខាន់ផ្សេងៗទៀតដើម្បីបង្កើតសិទ្ធិ។ ចំពោះសេចក្ដីបញ្ជាក់ដំបូងតម្រូវឲ្យមានភាពជា

[២២] មាត្រា ៥៣៩ និងមាត្រា ៧៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[២៣] មាត្រា៥៤៦ វាក្យខណ្ឌទី២ និង មាត្រា ៥៦៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

បន្ទាន់ ជាសេចក្តីបញ្ជាក់ដំបូងដែលមានកំរិតទាប ហើយចំពោះភស្តុតាងវិញគេកំណត់ឲ្យពិនិត្យភស្តុតាងដែលអាចពិនិត្យបានភ្លាមៗតែប៉ុណ្ណោះ។ សិទ្ធិនិងទំនាក់ទំនងគតិយុត្តនេះមានប្រភេទខុសគ្នាទៅតាមកម្មវត្ថុនៃការទាមទារ ដូចជាករណីចលនវត្ថុ ឬអចលនវត្ថុជាដើម។

ភាពចាំបាច់នៃការរក្សាការពារ ដោយយល់ឃើញពីផលប្រយោជន៍ក្នុងការធ្វើបណ្តឹង ជាពិសេសក្នុងការចាត់ចែងរក្សាការពារ ភាគីត្រូវធ្វើយ៉ាងណាដើម្បីបង្ហាញពីភាពចាំបាច់នៃការរក្សាការពារដែលជាមូលហេតុដែលអ្នកដាក់ពាក្យសុំ ត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់ពីតម្រូវការចាំបាច់ដើម្បីឲ្យតុលាការជឿជាក់រហូតដល់ចេញ ដីកាសម្រេចរក្សាការពារបាន។ ជាពិសេសព័ត៌មានដែលម្ចាស់បំណុលមានដែលទាក់ទងនិងស្ថានភាពនៅក្នុងហានិភ័យ លើទ្រព្យសម្បត្តិរបស់កូនបំណុល។ លើសពីនេះទៅទៀត អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារមួយចំនួនដូចជា ឯកសារបញ្ជាក់ដំបូងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ឯកសារបញ្ជាក់ដំបូងអំពីភាពចាំបាច់នៃការរក្សាការពារ ឯកសារដើម្បីបញ្ជាក់របស់អ្នកតំណាងដោយអាណត្តិ ឯកសារបញ្ជាក់ពីការរឹបអូសជាបណ្តោះអាសន្នជាដើម។

ឧទាហរណ៍ ៖ ក្រុមប្រឹក្សាភិបាលនៃមជ្ឈបណ្ឌល ក មួយ (ជាអង្គការក្រៅរដ្ឋាភិបាល) បានជួលលោកស្រី ខ ឲ្យធ្វើជានាយិកានៃមជ្ឈបណ្ឌលនោះ។ លោកស្រី ខ មិនគោរពគោលការណ៍របស់ក្រុមប្រឹក្សាភិបាលទេ ដូចជាមិនចូលរួមក្នុងការប្រជុំ តាមការអញ្ជើញរបស់ក្រុមប្រឹក្សាភិបាលជាដើមហេតុធ្វើឲ្យប្រទេសផ្តល់ជំនួយផ្តាច់ជំនួយដល់មជ្ឈមណ្ឌល។ ក្រុមប្រឹក្សា ដែលមានឈ្មោះ គ បានដាក់ពាក្យសុំដីកាសម្រេចរក្សាការពារហាមឃាត់លោកស្រី ខ មិនឲ្យធ្វើជានាយិកាមជ្ឈមណ្ឌល ហើយ គ សុំធ្វើជានាយិកានៃមជ្ឈមណ្ឌលជំនួសជាបណ្តោះអាសន្ន។ ដោយនៅក្នុងពាក្យសុំរបស់ គ បានបញ្ជាក់ថាមជ្ឈមណ្ឌលមានបទបញ្ជាក្នុងការបណ្តេញនាយិកា នោះចេញ ហើយនាយិកានោះ ត្រូវបានបណ្តេញចេញដោយយោងតាមបទបញ្ជានោះ។ ហើយនៅក្នុងពាក្យសុំរបស់ គ ក៏បាន បំពេញនូវធាតុពីរយ៉ាងគឺទី១ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលនឹងត្រូវបានរក្សាការពារ និង ទី២ គឺភាពចាំបាច់នៃការរក្សាការពារ។ ដោយសារតែការពារនូវភាពខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ ដែលនឹងកើតមានដល់ម្ចាស់បំណុល នោះភាគីចាំបាច់នៃការរក្សាការពារនឹងត្រូវបានគេទទួលស្គាល់។ ដោយសារតែករណីដែលល័ក្ខខ័ណ្ឌទាំងពីរនេះ គឺ(ទី១ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ និងទី ២ គឺភាពចាំបាច់នៃការរក្សាការពារ) ត្រូវបានបំពេញហើយតុលាការ អាចចេញដីកាបាន។

ឧទាហរណ៍ ៖ ប បានខ្ចីប្រាក់ពីធនាគារ រ ដោយដាក់បញ្ចាំប្លង់ផ្ទះនៅធនាគារ រ។ រ បានបង្កើតកិច្ចសន្យាហ៊ីប៉ូតែកជាមួយនឹង ប។ ប ដោយសារតែមានលិខិតកាន់កាប់ ក៏បានលក់ផ្ទះនោះទៅឲ្យ ទ។ ត្រង់ចំណុចនេះ រ មិនអាចដាក់ពាក្យសុំដីកាសម្រេចរក្សាការពារហាមមិនឲ្យ ទ លក់ ដូរ ឬ ផ្ទេរ បានទេ។ ព្រោះក្នុងករណីដែល រ បានធ្វើកិច្ចសន្យាហ៊ីប៉ូតែកដោយលិខិតយថាភូត និងបានចុះបញ្ជីហ៊ីប៉ូតែក

នោះមុនពេលដែល ប លក់ផ្ទះរបស់គាត់ទៅឲ្យ ទ។ រ អាចយកលិខិតហ៊ីប៉ូតែករបស់គាត់តតាំងចំពោះ ទ បាននៅក្នុងករណីនេះប្រសិនបើ ទ លក់ផ្ទះនោះឲ្យ ន។ រ ក៏អាចយកហ៊ីប៉ូតែករបស់គាត់មកតតាំងជាមួយនឹង ទ បានដែរ។ ដូច្នេះមិនមានភាពចាំបាច់ទេចំពោះ រ ក្នុងការដាក់ពាក្យសុំរក្សាការពារ ខាងលើពាក្យសុំនោះនឹងត្រូវបានលើកចោលដោយសារតែគ្មានភាពចាំបាច់ដើម្បីរក្សាការពារ។

ក្នុងករណីដែល រ មិនបានចុះបញ្ជីហ៊ីប៉ូតែករហូតដល់ពេលដែល ប លក់ផ្ទះរបស់គាត់ឲ្យទៅ ទ។ រ មិនអាចយកហ៊ីប៉ូតែកនោះមកតតាំងចំពោះ ទ បានឡើយ។ ដូច្នេះប្រសិនបើ រ ដាក់ពាក្យសុំដីកាសម្រេចរក្សាការពារ ហាមមិនឲ្យ ទ លក់ដូរ បញ្ចាំ ឬ ផ្ទេរ ពាក្យសុំនោះនឹងត្រូវលើកចោល។

សរុបមក រ មិនអាចដាក់ពាក្យសុំដីកាសម្រេចរក្សាការពារ ហាមមិនឲ្យ ទ លក់ដូរ បញ្ចាំ ឬផ្ទេរផ្ទះនោះបានឡើយ។

# ជំពូកទី ២

# ការចាត់ចែង និងការអនុវត្ត ជាបណ្តោះអាសន្ន

## ផ្នែកទី១ ប្រភេទ លក្ខខណ្ឌ និងនីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្ន

### កថាភាគទី១ ប្រភេទនៃការចាត់ចែងជាបណ្តោះអាសន្ន

ការចាត់ចែងជាបណ្តោះអាសន្ន មានពីរប្រភេទ៖ ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន[២៤]។ ទោះបីជាមានគោលបំណង និង ចរិតលក្ខណៈ ខុសគ្នាក៏ដោយ ក៏ការចាត់ចែងជាបណ្តោះអាសន្នទាំងពីរនេះ ស្ថិតនៅក្នុងប្រភេទនៃការចាត់ចែងរក្សាការពារ ហើយសិទ្ធិដែលត្រូវរក្សាការពារ គឺជាសិទ្ធិទាមទារដែលគ្មានគោលបំណងឲ្យសងជាប្រាក់ដូចគ្នា។ ហេតុនេះហើយ ការចាត់ចែងជាបណ្តោះអាសន្នទាំងពីរនេះ ត្រូវធ្វើតាមនីតិវិធីដូចគ្នា។

### កថាភាគទី២ លក្ខខ័ណ្ឌនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

សិទ្ធិដែលត្រូវបានរក្សាការពារ ៖ គោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺដើម្បីរក្សាស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនោះ។ ហេតុនេះហើយ សិទ្ធិទាមទារដែលត្រូវបានរក្សាការពារដោយការចាត់ចែងជាបណ្តោះអាសន្ននេះ ត្រូវមានខ្លឹមសារជាការផ្លាស់ប្តូរ ឬ មិនផ្លាស់ប្តូរនូវស្ថានភាពជាក់ស្តែង ឬ ទំនាក់ទំនងសិទ្ធិដែលមានលើវត្ថុ[២៥]។ សិទ្ធិដែលត្រូវបានរក្សាការពារ រួមមាន សិទ្ធិទាមទារឲ្យចុះបញ្ជីអំពីសិទ្ធិដែលមានលើវត្ថុ សិទ្ធិទាមទារឲ្យបណ្តេញបុគ្គលចេញពីដី ឬ អាគារ សិទ្ធិទាមទារឲ្យដកចេញនូវការសាងសង់ សិទ្ធិទាមទារឲ្យចុះបញ្ជីអំពីសិទ្ធិដែលមានលើវត្ថុ សិទ្ធិទាមទារមិនឲ្យធ្វើសកម្មភាពដែលពាក់ព័ន្ធនឹងការប្រើប្រាស់វត្ថុ ជាអាទិ៍។

<u>ឧទាហរណ៍</u> ៖ គំរូនៃការចាត់ចែងជាបណ្តោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ រួមមាន ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់អចលនវត្ថុ ដើម្បីរក្សាការពារសិទ្ធិទាមទារឲ្យបណ្តេញចេញពីអចលនវត្ថុនោះ ការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ដើម្បីរក្សាការពារសិទ្ធិទាមទារឲ្យចុះបញ្ជីអំពីសិទ្ធិលើអចលនវត្ថុ ជាអាទិ៍។ សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ដែលមានគោលបំណងជាការចាត់ចែង ដូចជា

[២៤] មាត្រា៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[២៥] វត្ថុនេះ ហៅថា «វត្ថុដែលជាកម្មវត្ថុនៃវិវាទ» ។

អនុប្បទាន[២៦] និង ការប្រមូល ត្រូវចាត់ទុកដូចជាវត្ថុ ហើយដោយហេតុនេះ អាចក្លាយជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្នប្រភេទនេះបាន ។

ភាពចាំបាច់នៃការរក្សាការពារ ៖ ភាពចាំបាច់នៃកាចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ត្រូវបានទទួលស្គាល់ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុដែល ជាកម្មវត្ថុនៃវិវាទ[២៧]។ ករណីនេះ រួមមានករណីដែលមានហានិភ័យនៃការខូចខាត ការគៃបំបាត់ ការផ្ទេរ ឬ ការរារាំងសិទ្ធិ លើវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយកូនបំណុល ឬ អ្នកផ្សេង ករណីដែលបុគ្គលណាម្នាក់កំពុងបន្តដំណើរនៃការសាងសង់ ក្នុងខណៈដែលមានការទាមទារ ឲ្យដកចេញនូវការ សាងសង់នោះ ការដែលបុគ្គលម្នាក់នាំ បុគ្គលម្នាក់ផ្សេងទៀត រួមទាំងឥវ៉ាន់របស់គេ មករស់នៅជាមួយ ក្នុងខណៈដែលមានការទាមទារឲ្យបណ្ដេញចេញពីផ្ទះនោះ។ ករណីដែល បុគ្គលម្នាក់ចាប់ផ្ដើមការសាបព្រួស ក្នុងខណៈដែលមានការទាមទារឲ្យប្រគល់ដី កសិកម្មនោះ ជាអាទិ៍ ។

**កថាភាគទី៣ លក្ខខណ្ឌនៃការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន**

សិទ្ធិដែលត្រូវបានរក្សាការពារ ៖ ការចាត់ចែងជាបណ្ដោះអាសន្ន ដែលកំណត់ឋានៈជាបណ្ដោះអាសន្នរួមបញ្ចូលនូវការចាត់ចែងជាច្រើនប្រភេទ។ ហេតុនេះហើយ សិទ្ធិទាមទារដែលត្រូវបានរក្សាការពារដោយការចាត់ចែងជាបណ្ដោះអាសន្នប្រភេទនេះក៏មានច្រើនដែរ។ សិទ្ធិដែលត្រូវបានរក្សាការពារ អាចជាសិទ្ធិលើទ្រព្យសម្បត្តិ ឬសិទ្ធិដែលទាក់ទងនឹងឋានៈបុគ្គល[២៨]។

<u>ឧទាហរណ៍</u> ៖ ទំនាក់ទំនងសិទ្ធិផ្ដាច់មុខ ដូចជា កម្មសិទ្ធិកាន់កាប់ សេរីភាព សិទ្ធិលើនាម និង សិទ្ធិលើប្រកាសនីយប័ត្រក្កកម្ម ទំនាក់ទំនងបន្តរវាងសិទ្ធិប្រត្យក្សដូចជា ទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា និង កម្មសិទ្ធិអវិភាគ ទំនាក់ទំនងគតិយុត្តដែលបន្ត ដូចជាកិច្ចសន្យាក្រុមហ៊ុន ភតិសន្យាការងារ និង ការផ្គត់ផ្គង់ (អាហារកាតព្វកិច្ច) និង ទំនាក់ទំនងឋានៈបុគ្គលដូចជា ទំនាក់ទំនងអាពាហ៍ពិពាហ៍ និង ទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន។ ចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឲ្យសងជាប្រាក់ ប្រសិនបើគោលបំណងនៃការរក្សាការពារ មិនមែនដើម្បីរក្សាការពារនូវការអនុវត្តដោយបង្ខំ នាពេល

[២៦] អនុប្បទានការផ្ទេរសិទ្ធ ឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលជាអនុប្បទាយី ទៅអោយបុគ្គលម្នាក់ទៀត ដែលជាអនុប្បទានិក ទំព័រ ២៧ នៃសន្ទានុក្រម ផ្នែករដ្ឋប្បវេណីក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៦ ។

[២៧] មាត្រា ៥៤៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[២៨] សិទ្ធិដែលទាក់ទងនឹងឋានៈបុគ្គល គឺជាសិទ្ធនៃទំនាក់ទំនងនៃក្រុមគ្រួសារមានដូចជា ប្ដីប្រពន្ធ, ឪពុកម្ដាយកូន មាត្រា៣ នៃច្បាប់ស្ដីពីនីតិវិធីទាក់ទងនឹងឋានៈបុគ្គល និងសេចក្ដីកំណត់ចំពោះមាត្រានីមួយៗឆ្នាំ ២០០៤ ។

អនាគតទេ តែគឺដើម្បីទប់ស្កាត់ និង ដកចេញនូវគ្រោះថ្នាក់ ឬ ការខូចខាតពិសេសដែលកើតឡើង ពីការមិនអនុវត្តកាតព្វកិច្ចនៃសិទ្ធិទាមទារ ដោយសារមានវិវាទអំពីអត្ថិភាពនៃសិទ្ធិទាមទារនោះ គេអាចទាមទារ ឲ្យផ្តល់តាវកាលិកទាំងស្រុង ឬមួយផ្នែកតាមនីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្នបាន ។

ឧទាហរណ៍ ៖ ករណីដែលបុគ្គលណាម្នាក់ពិបាកនឹងរស់នៅដោយគ្មានការផ្គត់ផ្គង់ (អាហារកាតព្វកិច្ច) ឬការបើកប្រាក់បៀវត្ស ករណីដែលបុគ្គលណាម្នាក់ពិបាកនិងទទួលបានការព្យាបាល ឬមិនងាយនឹងជាពីជំងឺប្រសិនបើគ្មានការទទួលការសងប្រាក់ធានារ៉ាប់រង ជាអាទ៏។

ត្រង់ចំណុចនេះ មានបញ្ហាមួយទាក់ទងទៅនឹងការចាត់ចែងជាបណ្តោះអាសន្ន ដែលសម្រេចសិទ្ធិតែម្តង។ ការចាត់ចែងបែបនេះ សំដៅទៅលើការចាត់ចែងជាបណ្តោះអាសន្នដែលសម្រេចតាមខ្លឹមសារនៃសិទ្ធិទាមទារលើអង្គសេចក្តីតែម្តង។ ចំណុចដែលថា ការចាត់ចែងជាបណ្តោះអាសន្ន ដែលសម្រេចសិទ្ធិតែម្តង អាចមានលទ្ធផលដូចជា ការទទួលស្គាល់ការអនុវត្តជាបណ្តោះអាសន្ននោះអាចធ្វើឲ្យគេគិតថា ការសម្រេចនោះលើសពីគោលបំណងនៃការចាត់ចែងបណ្តោះអាសន្ន។ ក៏ប៉ុន្តែ ជាទូទៅការចាត់ចែងបែបនេះ ត្រូវបានចាត់ទុកថាស្របច្បាប់ ព្រោះថាការចាត់ចែងជាបណ្តោះអាសន្ន ដែលកំណត់ឋានៈជាបណ្តោះអាសន្ន មានគោលបំណងដើម្បីកំណត់ឋានៈជាបណ្តោះអាសន្ន ដោយផ្អែកលើការសន្មតថា សិទ្ធិទាមទារទាំងមូល ឬ មួយផ្នែកមានអត្ថិភាពក្នុងគោលបំណងដកចេញនូវគ្រោះថ្នាក់ពិសេស និង ក្តីបារម្ភដែលកើតមានចំពោះម្ចាស់បំណុល ពីការមិនសម្រេចសិទ្ធិទាមទារ ដោយសារមានវិវាទអំពីអត្ថិភាពនៃសិទ្ធិនោះហើយបង្គាប់ឲ្យកូនបំណុលអនុវត្តកាតព្វកិច្ចនៃសិទ្ធិទាមទារនោះ។ មានន័យថា គោលបំណងរបស់វា មិនមែនដើម្បីរក្សាការពារនូវការអនុវត្តដោយបង្ខំនាពេលអនាគតនោះទេ ។

ឧទាហរណ៍ ៖ ករណីដែលនិយោជិតដែលធ្វើការអះអាងអំពីមោឃភាពនៃការបណ្តេញចេញដោយនិយោជក សុំឲ្យធ្វើការចាត់ចែងជាបណ្តោះអាសន្ន ដោយបង្គាប់ឲ្យនិយោជកនោះ ផ្តល់ប្រាក់ខែឲ្យខ្លួនចំនួនពាក់កណ្តាល រហូតដល់ពេលដែលបណ្តឹងអង្គសេចក្តីត្រូវបានសម្រេច ព្រោះថានិយោជិតនោះនឹងជួបការលំបាកយ៉ាងខ្លាំងក្នុងការរស់នៅ ប្រសិនបើមិនបានបើកប្រាក់ខែ ក្នុងខណៈដែលវិវាទនោះកំពុងត្រូវបានដោះស្រាយទេនោះ។

ភាពចាំបាច់នៃការរក្សាការពារ ៖ ភាពចាំបាច់នៃការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ត្រូវបានទទួលស្គាល់ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ[២៩]។

[២៩] មាត្រា ៥៤៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

ឧទាហរណ៍ ៖ ករណីដែលការខូចខាតដែលមិនអាចជួសជុលបាន កំពុងកើតឡើងចំពោះម្ចាស់បំណុល ដោយសារការចុះផ្សាយជាសាធារណៈនូវអត្ថបទទស្សនាវដ្ដីដែលមានលក្ខណៈជាការបរិហាកេរ្ដិ៍ ករណីដែលមានការបារម្ភអំពីគ្រោះថ្នាក់ដល់សុខភាពរបស់ម្ចាស់បំណុល ដែលបង្កឡើងដោយសម្លេងនៃការសាងសង់ ជាអាទិ៍។

**កថាភាគទី៤ វិធីនៃការចាត់ចែងជាបណ្ដោះអាសន្ន**

ខុសគ្នាពីការរឹបអូសជាបណ្ដោះអាសន្ន ការចាត់ចែងជាបណ្ដោះអាសន្ន មិនអាចបំពេញគោលបំណងរបស់វា ដោយវិធីតែមួយនៃការរឹបអូសយកទ្រព្យសម្បត្តិនោះឡើយ។ ហេតុនេះហើយវិធី និងកម្រិតនៃការចាត់ចែងជាបណ្ដោះអាសន្ន អាចនឹងមិនអាស្រ័យទៅតាមដំណាក់កាលនៃការអនុវត្តទេ តែត្រូវកំណត់នៅក្នុងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នទៅវិញ។ ជាពិសេស ការចាត់ចែងជាបណ្ដោះអាសន្នមួយចំនួន ដែលកំណត់ឋានៈជាបណ្ដោះអាសន្ន គ្រាន់តែបង្កើតនូវឋានៈគតិយុត្តនៅក្នុងការសម្រេចសេចក្ដីប៉ុណ្ណោះ គឺមិនបង្កើតបញ្ហានៃការអនុវត្តទេ[៣០]។

តុលាការអាចចាត់ចែងឲ្យកូនបំណុលធ្វើ ឬមិនធ្វើអំពើណាមួយជាកំណត់ ឬឲ្យកូនបំណុលផ្ដល់តាវកាលិក ឬ ឲ្យអ្នកថែរក្សាគ្រប់គ្រង វត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន ឬ ធ្វើការចាត់ចែងជាបណ្ដោះអាសន្ន[៣១]។ តុលាការ មានឆន្ទានុសិទ្ធិនៅក្នុងការជ្រើសរើសវិធីនៃការចាត់ចែងជាបណ្ដោះអាសន្ន។ ក៏ប៉ុន្តែ ការសម្រេចរបស់តុលាការ ត្រូវស្របទៅតាមវិធានដូចខាងក្រោមនេះ ៖

កម្រិត និង វិធីសាស្ត្រនៃការចាត់ចែងជាបណ្ដោះអាសន្ន ត្រូវស្ថិតនៅក្នុង ទំហំនៃពាក្យសុំរបស់ម្ចាស់បំណុល។ ទោះបីជាម្ចាស់បំណុលមិនចាំបាច់ត្រូវកំណត់ឲ្យច្បាស់លាស់នៅ ក្នុងពាក្យសុំ អំពីខ្លឹមសារជាក់លាក់នៃការចាត់ចែងជាបណ្ដោះអាសន្នក៏ដោយ ក៏យ៉ាងហោចណាស់ ម្ចាស់បំណុលត្រូវបញ្ជាក់អំពីគោលបំណងដែលខ្លួនត្រូវការឲ្យសម្រេច ដោយការចាត់ចែងជាបណ្ដោះអាសន្នដែរ។

វិធីសាស្ត្រដែលត្រូវជ្រើសរើសដោយតុលាការ ចាំបាច់ត្រូវតែជាអ្វីដែលអាចទាមទារចំពោះកូនបំណុល ឬអាចអនុវត្តបានចំពោះ កូនបំណុល ដោយការទាមទារនៅក្នុងបណ្ដឹងអង្គសេចក្ដី។ ប្រសិនបើការទាមទារសំណង គឺជាវិធីតែមួយគត់ ដែលអាចធ្វើបាននៅក្នុងការទាមទារផ្នែកអង្គសេចក្ដី សិទ្ធិទាមទារនោះ គួរតែត្រូវបានរក្សាការពារដោយការរឹបអូសជាបណ្ដោះអាសន្ន ហើយដោយហេតុនេះ គេមិនអាចដាក់ពាក្យសុំឲ្យ ចាត់ចែងជាបណ្ដោះអាសន្នបានទេ។ ម្យ៉ាងទៀត តុលាការ អាចបង្គាប់ឲ្យកម្រិតក្នុងការធ្វើសកម្មភាព ឬ បង្គាប់ឲ្យផ្ដល់តាវកាលិក ចំពោះតែកូនបំណុលតតិយជនផ្សេងទៀត ដែលត្រូវ

[៣០] ជាការចាត់ចែងជាបណ្ដោះអាសន្ន ដែលរំពឹងថាកូនបំណុលអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត ។

[៣១] មាត្រា ៥៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

ទទួលអានុភាពអនុវត្តនៃលិខិតអនុវត្តដែលទាក់ទងនឹងសិទ្ធិទាមទារផ្អែកអង្គសេចក្តីប៉ុណ្ណោះ ពោលគឺមិនអាចធ្វើការចាត់ចែងណាដែលជះឥទ្ធិពលដោយផ្ទាល់ទៅដល់សិទ្ធិ និង ឋានៈគតិយុត្តរបស់តតិយជនផ្សេងទៀតបានឡើយ។ ក៏ប៉ុន្តែ ក្នុងករណីដែលតតិយជន ត្រូវបានតម្រូវឲ្យទទួលស្គាល់ ឋានៈរបស់កូនបំណុល ដែលត្រូវចេងដោយការ ចាត់ចែងជាបណ្តោះអាសន្ន តតិយជននោះអាចនឹងទទួលរងនូវឥទ្ធិពលពីការចាត់ចែងនោះ។ ករណីបែបនេះ កើតមានច្រើននៅក្នុងការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន។

<u>ឧទាហរណ៍</u> ៖ បើមានការចាត់ចែងចំពោះសហគ្រាសណាមួយ ដែលកំណត់អ្នកប្រតិបត្តិកិច្ចជំនួសនាយកនោះ តតិយជន ក៏ត្រូវទទួលស្គាល់សិទ្ធិអំណាច របស់អ្នកប្រតិបត្តិកិច្ចការជំនួសនេះ។

វិធីសាស្ត្រនៃការចាត់ចែងជាបណ្តោះអាសន្នដែលជ្រើសរើសដោយតុលាការ ត្រូវស្ថិតនៅក្នុងទំហំដែលចាំបាច់ ដើម្បីសម្រេចនូវគោលបំណង នៃពាក្យសុំឲ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។ ជាពិសេស នៅក្នុងការចាត់ចែងជាបណ្តោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ការចាត់ចែងមួយចំនួនដូចជាការផ្តល់ទៅអោយម្ចាស់បំណុល នូវការសម្រេចសិទ្ធិ ដូចគ្នានឹងការសម្រេចសិទ្ធិនៅក្នុងការអនុវត្តដោយបង្ខំដែរ នោះគឺជាការធ្វើហួសពីគោលបំណងនៃការចាត់ចែងរក្សាការពារ។

វិធីសាស្ត្រជាក់លាក់នៃការចាត់ចែងជាបណ្តោះអាសន្នរួមមាន៖

១. «ការចាត់ចែងឲ្យកូនបំណុលធ្វើ ឬ មិនធ្វើអំពើណាមួយជាកំណត់» គឺជាការបង្គាប់ឲ្យកូនបំណុលធ្វើ ឬមិនធ្វើសកម្មភាពណាមួយ។

<u>ឧទាហរណ៍</u> ៖ ការបង្គាប់ឲ្យរុះរើសំណង់ ការហាមឃាត់មិនឲ្យសាងសង់ ការហាមឃាត់មិនឲ្យធ្វើចរាចរណ៍ ការហាមឃាត់មិនឲ្យបោះពុម្ពផ្សាយជាសាធារណៈ ជាអាទិ៍។

២. «ការចាត់ចែងឲ្យកូនបំណុលផ្តល់តាវកាលិក» សំដៅទៅលើការបង្គាប់ឲ្យធ្វើសកម្មភាពដែលអាចអនុវត្តដោយផ្ទាល់បាន ដូចជាការប្រគល់វត្ថុ ការបណ្តេញចេញពីអចលនវត្ថុ និង ការសងប្រាក់ ជាដើម។

៣. «ការចាត់ចែងឲ្យថែរក្សាគ្រប់គ្រង ដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន» មានន័យថា ជាការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ពីកូនបំណុល ទៅឲ្យអ្នកថែរក្សាគ្រប់គ្រង។ វិធីនេះត្រូវបានប្រើប្រាស់ជាញឹកញាប់ ដើម្បីថែរក្សានូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ។ ជាទូទៅ អាជ្ញាសាលា ត្រូវបានចាត់ឲ្យធ្វើជាអ្នកថែរក្សាគ្រប់គ្រង។ ក៏ប៉ុន្តែ ម្ចាស់បំណុល ឬតតិយជនក៏អាចធ្វើជាអ្នកថែរក្សាគ្រប់គ្រងបានដែរ។ ក្នុងករណីដែលបានចាត់អាជ្ញាសាលា ឲ្យធ្វើជាអ្នកថែរក្សាគ្រប់គ្រង តុលាការក៏អាចធ្វើការចាត់ចែងជាបណ្តោះអាសន្ន ដែលអនុញ្ញាតឲ្យកូនបំណុលអាចប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនោះបានដែរ។

៩. ការចាត់ចែងចាំបាច់ផ្សេងទៀត មានដូចជា ការហាមឃាត់មិនឲ្យកូនបំណុលទី ៣ សងនៅក្នុងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការប្រមូលបំណុល ការបង្គាប់ឲ្យប្រកាសជាសាធារណៈ អំពីការណ៍ដែលអាជ្ញាសាលាកំពុងថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុ នៃវិវាទដោយអាជ្ញាសាលា នៅក្នុងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលបង្គាប់ឲ្យអាជ្ញាសាលាធ្វើជាអ្នកថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាដើម។

## ផ្នែកទី ២ ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

### កថាភាគទី១ បញ្ញត្តិដែលអនុវត្តដូចគ្នាជាមួយនឹងការរឹបអូសជាបណ្ដោះអាសន្ន

បញ្ញត្តិដែលទាក់ទងទៅនឹងតុលាការមានសមត្ថកិច្ច ការដាក់ពាក្យសុំ វិធីនៃការវិនិច្ឆ័យ និង ការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដូចគ្នាទៅនឹងបញ្ញត្តិស្ដីពីការរឹបអូសជាបណ្ដោះអាសន្នដែរ លើកលែងតែមានបញ្ញត្តិពិសេស។

### កថាភាគទី២ តុលាការមានសមត្ថកិច្ច

ក្នុងការចាត់ចែងជាបណ្ដោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្រៅពីតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង ដែលវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះស្ថិតនៅ ក៏ជាតុលាការមានសមត្ថកិច្ចដែរ[៣២]។ ផ្ទុយទៅវិញ មានតែតុលាការនៃបណ្ដឹងអង្គសេចក្ដីទេដែលមានសមត្ថកិច្ចផ្ដាច់មុខ លើការចាត់ចែងជាបណ្ដោះអាសន្ន ដែលកំណត់ឋានៈជាបណ្ដោះអាសន្ន។

### កថាភាគទី៣ វិធីនៃការវិនិច្ឆ័យ

តុលាការ មិនអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលកំណត់ឋានៈជាបណ្ដោះអាសន្នបានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសាកសួរដែលកូនបំណុលអាចចូលរួមបាន[៣៣]។ ទោះបីជាមូលដ្ឋាន ការចាត់ចែងជាបណ្ដោះអាសន្នត្រូវធ្វើជាសម្ងាត់ដូចជាករណីនៃការរឹបអូសជាបណ្ដោះអាសន្នក៏ដោយ នៅក្នុងការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ផលប្រយោជន៍របស់ម្ចាស់បំណុលនៅតែត្រូវបានការពារទោះជាគ្មានការវិនិច្ឆ័យជាសម្ងាត់ក៏ដោយ ហើយម្យ៉ាងទៀត បើនីតិវិធីនេះធ្វើឡើងដោយសម្ងាត់នោះនឹងនាំអោយមានការប៉ះពាល់ធ្ងន់ធ្ងរដល់កូនបំណុល។ ហេតុនេះហើយបានជា

---

[៣២] មាត្រា ៥៤០ កថាខណ្ឌទី១. ចំពោះទីន្លែងនៃសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត សូមមើលកថាខណ្ឌទី ៣ និង ទី ៤ នៃមាត្រាដដែរ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[៣៣] មាត្រា ៥៤៨ កថាខណ្ឌទី ៤ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

ច្បាប់ផ្តល់ឱកាស ឲ្យដល់កូនបំណុលក្នុងការការពារខ្លួន នៅក្នុងការចាត់ចែងជាបណ្តោះអាសន្នប្រភេទនេះ (ចំណុចប្រហាក់ប្រហែលទៅនឹងដីកាកិច្ចការប្រញាប់ (REFERE) នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបារាំងដែរ) ។ ក៏ប៉ុន្តែ ប្រសិនបើមានស្ថានភាពពិសេសដែលនាំឲ្យពុំអាចសម្រេចគោលបំណង នៃពាក្យសុំឲ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារឆ្លងតាមការបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ នោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន អាចចេញបានដោយមិនចាំបាច់ឆ្លងតាមកាលបរិច្ឆេទនៃការទាមទារ ហេតុផលដោយផ្ទាល់មាត់ទេ[៣៤]។

<u>ឧទាហរណ៍</u> ៖ ក្នុងករណីដែលទស្សនាវដ្តីមានផ្ទុកនូវអត្ថបទបរិហារកេរ្តិ៍ និង ត្រូវចេញផ្សាយជាសាធារណៈនៅថ្ងៃបន្ទាប់ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចេញផ្សាយជាសាធារណៈនោះនិងមិនអាចធ្វើទៅរួចឡើយ ប្រសិនបើត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់សិន។

**កថាភាគទី៤ ដីកាសម្រេច**

ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ខុសគ្នាពីការរឹបអូសជាបណ្តោះអាសន្ន ពុំមានការចាត់ចែងជាបណ្តោះអាសន្នណាមួយដែលកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវធ្វើ ដើម្បីលុបចោលការអនុវត្តការចាត់ចែង (ប្រាក់រំដោះ) នោះឡើយ ព្រោះថាគោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្ន មិនមែនដើម្បីរក្សាការពារនូវការអនុវត្តដោយបង្ខំឲ្យសងជាប្រាក់ទេ។

## ផ្នែកទី៣ ការតវ៉ាចំពោះការចាត់ចែង និងការអនុវត្តជាបណ្តោះអាសន្ន

### កថាភាគទី១ ឧបាស្រ័យចំពោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន

#### ១. បញ្ញត្តិដែលអនុវត្តដូចគ្នា ជាមួយនិងការរឹបអូស ជាបណ្តោះអាសន្ន

របៀបធ្វើឧបាស្រ័យចំពោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ត្រូវអនុវត្តតាមបញ្ញត្តិដូចគ្នា និង របៀបធ្វើឧបាស្រ័យចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែល រួមមាន ពាក្យសុំតវ៉ា ពាក្យសុំទាមទារ ឲ្យលុបចោល និងបណ្តឹងជំទាស់ ដែរលើកលែងតែមានបញ្ញត្តិពិសេស ។

#### ២. អនុភាពនៃការលុបចោលដីកាចាត់ចែងជាបណ្តោះអាសន្ន

នៅក្នុងករណីដែលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដែលបានចេញម្តងហើយ ត្រូវលុបចោលវិញ ដោយសារពាក្យសុំតវ៉ា ពាក្យសុំទាមទារឲ្យលុបចោល ឬ បណ្តឹងជំទាស់ ប្រសិនបើម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬការបង់ប្រាក់ ឬកំពុងប្រើប្រាស់ ឬថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននោះ តុលាការអាចបង្គាប់ឲ្យម្ចាស់បំណុល បង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬ សងប្រាក់ដែលកូនបំណុលបានបង់ ឬបង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុង

[៣៤] មាត្រា ៥៤៨ កថាខណ្ឌទី ៤វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

ប្រើប្រាស់ ឬ ថែរក្សាគ្រប់គ្រងនៅក្នុងដីកាសម្រេចលុបចោលនោះបានតាមពាក្យសុំរបស់កូនបំណុល[៣៥]។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថាប្រសិនបើដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលផ្លាស់ប្ដូរនូវស្ថានភាពដើមត្រូវបានអនុវត្តហើយ ស្ថានភាពដើមនោះមិនអាចធ្វើបដិទាន[៣៦]បានវិញឡើយដោយគ្រាន់តែលុបចោលដីកាសម្រេចចាត់ចែងដោយបណ្ដោះអាសន្ននោះទេ។ ហេតុនេះហើយ តុលាការ ត្រូវតែអាចបង្គាប់ឲ្យធ្វើបដិទាននូវស្ថានភាពដើម នៅក្នុងដីកាសម្រេចលុបចោល។ បណ្ដឹងជំទាស់អាចធ្វើឡើងដោយឯករាជ្យបាន ចំពោះដីកាសម្រេចទាំងនេះ[៣៧]។

## ៣. ការលុបចោលការចាត់ចែងជាបណ្ដោះអាសន្នដោយសារស្ថានភាពពិសេស

ស្រដៀងគ្នាទៅនិងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដែរ ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន រួមមានការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដោយសារស្ថានភាពពិសេស។ មានន័យថា តុលាការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន តាមពាក្យស្នើសុំរបស់កូនបំណុលបាន ប្រសិនបើមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយសារការសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ មានស្ថានភាពពិសេសផ្សេងទៀត[៣៨]។ តុលាការដែលមានសមត្ថកិច្ច គឺតុលាការដែលបានចេញដីកាសម្រេច ចាត់ចែងជាបណ្ដោះអាសន្ន ឬតុលាការនៃបណ្ដឹងអង្គសេចក្ដី ។

ករណីដែលដីកាសម្រេចជាបណ្ដោះអាសន្ន អាចនឹងត្រូវបានលុបចោលដោយសារស្ថានភាពពិសេស ត្រូវបានបែកចែកជាពីរ ។ ករណីទីមួយ គឺករណីដែលគោលបំណងនៃការចាត់ចែងជាបណ្ដោះអាសន្នអាចសម្រេចបាន ដោយការសងជាប្រាក់ទៅឲ្យម្ចាស់បំណុល ។ ទោះបីជាទូទៅ ការសងជាប្រាក់សុទ្ធសាធ មិនអាចសម្រេចគោលបំណងនៃការចាត់ចែងជាបណ្ដោះអាសន្នបាន ព្រោះថាសិទ្ធិដែលត្រូវបានរក្សាការពារ ដោយការចាត់ចែងជាបណ្ដោះអាសន្ននោះ គឺជាសិទ្ធិទាមទារដែលគ្មានគោលបំណងឲ្យសងជាប្រាក់ក៏ដោយ ក៏ប៉ុន្តែក្នុងករណីដែលការចាត់ចែងជាបណ្ដោះអាសន្ននោះ មានមូលដ្ឋានជាសិទ្ធិទាមទារឲ្យសងជាប្រាក់ ឬ ករណីដែលមានសិទ្ធិទាមទារឲ្យសងជាប្រាក់ស្ថិតនៅពីក្រោយការចាត់ចែងជាបណ្ដោះអាសន្ននោះ ប្រសិនបើការសងជាប្រាក់ នឹងធ្វើឲ្យសម្រេចយ៉ាងជាក់ស្ដែងនូវសិទ្ធិ

[៣៥] មាត្រា ៥៥៥ , មាត្រា ៥៦០កថាខណ្ឌទី១ មាត្រា ៥៦១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៣៦] បដិទានការស្តារឡើងវិញនូវស្ថានភាពដើម ឬ ការប្រគល់ត្រឡប់វិញ ទំព័រ ១២ នៃសន្ទានុក្រមផ្នែករដ្ឋប្បវេណីនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ។

[៣៧] មាត្រា ៥៦១ កថាខណ្ឌទី១ ចំណុច ខ និងចំណុចគ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៣៨] មាត្រា ៥៥៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

ដែលត្រូវបានរក្សាការពារ នោះការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន អាចធ្វើបាន ដោយតម្រូវឲ្យដាក់ប្រាតិភោគ។

ឧទាហរណ៍ ៖ ដូចជា ករណីនៃការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងទ្រព្យសម្បត្តិរបស់អ្នកដែលបានទទួលផលប្រយោជន៍ ដើម្បីរក្សាការពារនូវសិទ្ធិរបស់ម្ចាស់បំណុល ក្នុងការទាមទារឲ្យលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ ដែលប្រព្រឹត្តឡើងដោយកូនបំណុលជាដើម។

ករណីទីពីរ គឺករណី បើគិតពីសមធម៌រវាងភាគីទាំងពីរ ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន បង្កឲ្យមានការខូចខាត ធ្ងន់ធ្ងរជាងការខូចខាតដែលកើតឡើងជាធម្មតាចំពោះកូនបំណុល។ ដោយគិតពិចារណាអំពីផលប្រយោជន៍របស់ម្ចាស់បំណុល និង កូនបំណុល ប្រសិនបើការខូចខាតចំពោះកូនបំណុលដែលមកពីការចាត់ចែងជាបណ្តោះអាសន្ន មានទំហំធំធេងខ្លាំងជាងការខូចខាតចំពោះម្ចាស់បំណុល ដែលបណ្តាលមកពីការមិនអនុវត្តចាត់ចែងជាបណ្តោះអាសន្ន ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននោះផ្ទុយនឹងគោលការណ៍សមធម៌ហើយ ។

ឧទាហរណ៍ ៖ ករណីដែលការចាត់ចែងជាបណ្តោះអាសន្ន ដោយការដែលអាជ្ញាសាលាទៅថែក្សារក្សា គ្រប់គ្រងចលនវត្ថុ ដែលកូនបំណុលកំពុងលក់ដូរ ធ្វើឲ្យកូនបំណុលនោះមិនអាចធ្វើអាជីវកម្ម ឬ មានការពិបាកយ៉ាងខ្លាំងក្នុងការបន្តអាជីវកម្មទៅមុខទៀត។ ចំពោះស្ថានភាពពិសេសទាំងនេះ កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង[៣៩]។

បញ្ញត្តិទាក់ទងទៅនឹងការសម្រេចសេចក្តី អំពីការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្តីអំពីពាក្យសុំអោយលុបចោលដោយសារស្ថានភាពពិសេសនេះ។ មានន័យថា បញ្ញត្តិស្តីពីការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្នរួមមាន[៤០] ៖

ក. ការទាញហេតុផលដោយផ្ទាល់មាត់ ឬការសួរនៅកាលបរិច្ឆេទដែលភាគីទាំងពីរអាចចូលរួមបាន[៤១]។

ខ. ការបញ្ចប់ការវិនិច្ឆ័យ[៤២]

---

[៣៩] បញ្ញត្តិចាប់ពីមាត្រា ៤២៨ និងមាត្រា ៥៥៩ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ។

[៤០] មាត្រា ៥៦០ កថាខណ្ឌទី ១ និងមាត្រា ៥៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ។

[៤១] មាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៤២] មាត្រា ៥៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

គ. អានុភាពនៃការសម្រេចដែលលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវយកមកអនុវត្តដូចគ្នា ចំពោះការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារស្ថានភាពពិសេសនេះ។ ជាងនេះទៅទៀត ដីកាសម្រេចបង្គាប់ឲ្យធ្វើបដិទាន ក៏អាចចេញបានដែរ នៅក្នុងករណីនេះ។ ដីកាសម្រេចលុបចោលនេះ ត្រូវចេញដោយដាក់ល័ក្ខខ័ណ្ឌតម្រូវឲ្យកូនបំណុលដាក់ប្រាតិភោគ។ ដីកាសម្រេចអំពីពាក្យសុំឲ្យលុបចោល ត្រូវបញ្ជូនទៅឲ្យភាគី ហើយចំពោះដីកាសម្រេចនេះ អាចប្ដឹងជំទាស់បាន[៤៣]។

## កថាភាគទី២ ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន

### ១. បញ្ញត្តិដែលអនុវត្តដូចគ្នាជាមួយនឹងការរឹបអូសជាបណ្ដោះអាសន្ន

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ត្រូវអនុលោមតាមបញ្ញត្តិដូចគ្នានឹងការអនុវត្តរឹបអូសជាបណ្ដោះអាសន្នដែរ លើកលែងតែមានបញ្ញត្តិពិសេស។ ទោះជាយ៉ាងណាក៏ដោយ ដូចបានពន្យល់ពីខាងដើម ការចាត់ចែងជាបណ្ដោះអាសន្នមួយចំនួន ដែលគោលបំណងរបស់វាអាចសម្រេចបានដោយគ្រាន់តែបង្កើតឋានៈគតិយុត្តដោយដីកាសម្រេច ហើយរង់ចាំឲ្យកូនបំណុលអនុវត្តកាតព្វកិច្ច ដោយស្ម័គ្រចិត្ត នោះមិនត្រូវការឲ្យមានការអនុវត្ត។ ដោយឡែក ការចាត់ចែងជាបណ្ដោះអាសន្ន មួយចំនួនទៀត ដូចជា ការចាត់ចែងជាបណ្ដោះអាសន្នដែលគ្រាន់តែបង្គាប់កូនបំណុលមិនឲ្យធ្វើសកម្មភាព អ្វីមួយ ជាដើមក៏មិនត្រូវការឲ្យមានការអនុវត្តដែរ លើកលែងតែករណីដែលកូនបំណុលបំពានករណីយកិច្ចដែលបានបង្គាប់នោះ។

### ២. វិធីនៃការអនុវត្ត

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធីអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ឬ វិធីអនុវត្តដោយបង្ខំដែរ[៤៤]។ ដោយសារថាវិធីចាត់ចែងជាបណ្ដោះអាសន្ន មានច្រើន[៤៥] ដូច្នេះទើបពុំមានបញ្ញត្តិចែងឲ្យបានជាក់លាក់អំពីវិធីនៃការអនុវត្តទេ។ វិធីនៃការអនុវត្តនីមួយៗ ត្រូវអនុលោមទៅតាមវិធីដែលមានកំណត់ច្បាស់លាស់នៅក្នុងសេចក្ដីសម្រេចបញ្ជប់ នៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ។

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលបង្គាប់ឲ្យសងជាប្រាក់ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់។ ការអនុវត្តចាត់ចែង

[៤៣] មាត្រា ៥៥៦ មាត្រា ៥៥៥ និង មាត្រា ៥៥៩ កថាខណ្ឌទី ១ កថាខណ្ឌទី ៣ និងមាត្រា ៥៦១ កថាខណ្ឌទី ១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៤៤] មាត្រា ៥៧០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៤៥] មាត្រា ៥៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

ជាបណ្ដោះអាសន្នដែលបង្គាប់ឲ្យប្រគល់ ឬ បណ្ដេញចេញពីអចលនវត្ថុ និង ចលនវត្ថុ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ និង ចលនវត្ថុ[៤៦]។ ចំណែកឯ ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលបង្គាប់ឲ្យកូនបំណុលធ្វើ ឬមិនធ្វើសកម្មភាពអ្វីមួយ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តជំនួស[៤៧] និងវិធានបង្ខំដោយប្រយោល[៤៨]។

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែងវត្ថុអ្វីមួយ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន។

បើដីកាសម្រេចដែលហាមឃាត់មិនឲ្យកូនបំណុលផ្ទេរការកាន់កាប់វត្ថុ និង បង្គាប់ឲ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឲ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឲ្យប្រគល់វត្ថុនោះត្រូវបានចេញ អាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់នោះ ហើយអាជ្ញាសាលា ថែរក្សា គ្រប់គ្រង វត្ថុនោះដោយបិទលិខិតប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬ ប្រកាសជាសាធរណៈ តាមរបៀបសមរម្យផ្សេងទៀត[៤៩]។ មានន័យថា បើបិទប្រកាសជាសាធារណៈនៅផ្នែកខាងក្នុងនៃអាគារដែលជាកម្មវត្ថុប្រកាសនោះ ត្រូវបិទភ្ជាប់ទៅនឹងជញ្ជាំងនៃអាគារនោះ ឬ នៅកន្លែង ណាផ្សេងដែលងាយនឹងមើលឃើញ។ បើបិទប្រកាសជាសាធារណៈនៅផ្នែកខាងក្រៅនៃអាគារ ឬ ប្រកាសជាសាធារណៈលើដីវិញ ក្ដារប្រកាសដែលរៀបរាប់អំពីខ្លឹមសារនៃការប្រកាសជាសាធារណៈនោះ ត្រូវដំភ្ជាប់នឹងសសរឈើដោយប្រើដែកគោល ឬ ត្រូវដាក់ភ្ជាប់នឹងជញ្ជាំងខាងក្រៅនៃអាគារដោយដំដែកគោល ឬវិធីផ្សេងៗទៀតភ្ជាប់នឹងជញ្ជាំងខាងក្រៅនៃអាគារ។

### ៣. អានុភាពនៃការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន

ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង ៖ បើការចាត់ចែងជាបណ្ដោះអាសន្នមានខ្លឹមសារជាការហាមឃាត់ការចាត់ចែងរបស់កូនបំណុល លើវត្ថុដែលជាកម្មវត្ថុនៃវិវាទ នោះស្រដៀងគ្នាទៅនឹងករណីនៃការរឹបអូសជាបណ្ដោះអាសន្នដែរ ការចាត់ចែងរបស់កូនបំណុលដែលធ្វើផ្ទុយនឹងការហាមឃាត់នេះ មិនអាចតាំងជាមួយនឹងម្ចាស់បំណុល នៃការចាត់ចែងជាបណ្ដោះអាសន្នបានឡើយ។ មានន័យថា តតិយជនដែលបានទទួលសិទ្ធិពីការចាត់ចែងនេះ មិនអាចយកលទ្ធកម្មនេះ

[៤៦] មាត្រា ៥២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៤៧] មាត្រា ៥២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៤៨] មាត្រា ៥២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៤៩] មាត្រា ៥៧១ កថាខណ្ឌទី ១នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

ទៅតតាំងជាមួយនឹងម្ចាស់បំណុលបានឡើយ ហើយលទ្ធកម្មនេះនឹងត្រូវបានចាត់ទុកថាពុំមានអត្ថិភាព នៅក្នុងការអនុវត្តដោយបង្ខំនៅពេលបន្ទាប់។

ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ៖ ក្នុងចំណោមការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ចំពោះការចាត់ចែងជាបណ្ដោះអាសន្នណាដែលមានការប្រកាសជាសាធារណៈដូចបានរៀបរាប់ខាងលើ។ បើមានការផ្ទេរការកាន់កាប់ដោយផ្ទុយនឹងការហាមឃាត់នេះ ការផ្ទេរនោះមិនអាចតតាំងជាមួយនឹងម្ចាស់បំណុលនៃការចាត់ចែងជាបណ្ដោះអាសន្នបានឡើយ។ ហេតុនេះហើយ ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឲ្យប្រគល់វត្ថុបាន ដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្ដី[៥០]។ នៅក្នុងបណ្ដឹងទាមទារឲ្យប្រគល់វត្ថុប្រសិនបើបណ្ដឹងនោះធ្វើឡើង ដោយយកអ្នកកាន់កាប់នៅពេលបណ្ដឹងកំពុងត្រូវបានចាត់ការធ្វើជាចុងចម្លើយអានុភាពនៃសាលក្រមនឹងមានទៅលើបុគ្គលដែលទទួលបន្តនូវការកាន់កាប់ នៅក្រោយពេលដែលបណ្ដឹងត្រូវបានចាត់ការ បើទោះបីជាមានការផ្ទេរការកាន់កាប់ក៏ដោយ[៥១]។ ក៏ប៉ុន្តែ អានុភាពនៃសាលក្រម មិនត្រូវមានទៅលើអ្នកកាន់កាប់ដែលមិនបានទទួលបន្តនូវសិទ្ធិកាន់កាប់ពីអ្នកកាន់កាប់ នៅពេលដែលបណ្ដឹងកំពុងត្រូវបានចាត់ការនោះទេ។

<u>ឧទាហរណ៍</u> ៖ ដូចជាអ្នកកាន់កាប់ខុសច្បាស់។

ម្យ៉ាងទៀត នៅក្នុងករណីដែលកម្មវត្ថុនោះគឺជាចលនវត្ថុ នោះក៏អាចនឹងកើតមាននូវករណីនៃលទ្ធកម្មដោយសុខចិត្តបានដែរ។ ហេតុនេះហើយ ច្បាស់អនុញ្ញាតឲ្យបុគ្គលដែលមានបំណងចង់ដាក់ពាក្យបណ្ដឹងទាមទារឲ្យប្រគល់វត្ថុ ឬបុគ្គលដែលបានដាក់ពាក្យបណ្ដឹងនោះហើយ អាចកំណត់ទំនាក់ទំនងនៃការកាន់កាប់បច្ចុប្បន្ន។ ទោះបីជាយ៉ាងណាក៏ដោយ ការពង្រីកអានុភាពនៃសាលក្រមតាមវិធីនេះ ត្រូវបានកម្រិតត្រឹមតែករណីដែលអ្នកកាន់កាប់ មានទុច្ចរិតអំពីអត្ថិភាពនៃការចាត់ចែងជាបណ្ដោះអាសន្នដែលពាក់ព័ន្ធ ពោលគឺករណីដែលអ្នកកាន់កាប់វត្ថុនោះ ដឹងថាមានការចាត់ចែងជាបណ្ដោះអាសន្នប៉ុណ្ណោះ[៥២]។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថា ទោះជាក្នុងករណីនៃលទ្ធកម្មនៃការកាន់កាប់មិនមែនជាការទទួលបន្តក៏ដោយ ក៏អ្នកកាន់កាប់ដោយទុច្ចរិត មិនត្រូវទទួលការការពារដែរ។ គួរបញ្ជាក់ថាជនដែលកាន់កាប់ ដែលចាប់ផ្ដើមការកាន់កាប់ ក្រោយពេលដែលការចាត់ចែងជាបណ្ដោះអាសន្ន ត្រូវបានប្រកាសជាសាធារណៈ ត្រូវសន្មត់ថាជាអ្នកកាន់កាប់ដោយទុច្ចរិត ហេតុនេះហើយ ដើម្បីតទល់នឹង

[៥០] មាត្រា ៥៧១ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។
[៥១] មាត្រា ១៩៨ ចំណុច គ និងមាត្រា ៣៥១ កថាខណ្ឌទី ១ ចំណុច គនៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។
[៥២] មាត្រា ៥៧១ កថាខណ្ឌទី២ វាក្យខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

ការសន្មត់នេះ អ្នកកាន់កាប់ត្រូវបញ្ជាក់អំពីភាពសុចរិតនៃការកាន់កាប់របស់ខ្លួន។ ក្នុងករណីដែលអ្នកកាន់កាប់វត្ថុដែលពាក់ព័ន្ធ ដោយមានសិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្តនៃការកាន់កាប់ ដែលអាចតតាំងជាមួយនឹងម្ចាស់បំណុល ដូចជា ករណីដែលជននេះមានសិទ្ធិជួល ដែលអាចតតាំងជាមួយនឹងម្ចាស់បំណុលបាន ឬក្នុងករណីដែលអ្នកកាន់កាប់ មិនបានដឹងអំពីការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ហើយមិនមែនជាអ្នកទទួលបន្តនូវការកាន់កាប់ពីកូនបំណុល ដូចជាករណីដែលជននោះកាន់កាប់វត្ថុដែលពាក់ព័ន្ធដោយមិនបានដឹងអំពីការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ព្រោះសេចក្ដីប្រកាសជាសាធារណៈ បានបកបាត់ ជាដើម។ អ្នកកាន់កាប់នេះ អាចអះអាង អំពីស្ថានភាពនេះ ដោយដាក់ពាក្យតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត[៥៣]។

ការចាត់ចែងជាបណ្ដោះអាសន្នដោយឡែកណា ដែលរារាំងអានុភាព នៃការចាត់ចែងជាបណ្ដោះអាសន្ន ឬ ដែលផ្អាកការចាត់ចែងជាបណ្ដោះអាសន្ន មិនត្រូវបានអនុញ្ញាតទេ។ ដើម្បីចាកចេញនូវការចាត់ចែងជាបណ្ដោះអាសន្ន កូនបំណុលត្រូវដាក់ពាក្យសុំទាមទារឲ្យលុបចោលដីកាសម្រេចចាត់ចែង ជាបណ្ដោះអាសន្ន ឬ ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ចំណែកតតិយជន ត្រូវដាក់ពាក្យបណ្ដឹងតវ៉ា របស់តតិយជន ឬ ដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត។ ទោះជាយ៉ាងណាក៏ដោយ ករណីដែលមាន ការចាត់ចែងជាបណ្ដោះអាសន្នច្រើនលើ កម្មវត្ថុតែមួយ មិនត្រូវបានហាមឃាត់ទេ ប្រសិនបើខ្លឹមសារនៃការចាត់ចែងជាបណ្ដោះអាសន្នទាំងនោះ មិនមានខ្លឹមសារផ្ទុយគ្នា។

<u>ឧទាហរណ៍</u> ៖ ករណីដែលការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង និងការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការផ្ទេរការកាន់កាប់ ត្រូវបានអនុវត្តចំពោះអចលនវត្ថុតែមួយ។

[៥៣] មាត្រា ៣៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

# ជំពូកទី៣

# ការរឹបអូស និង ការអនុវត្តជាបណ្តោះអាសន្ន

## ផ្នែកទី១ ល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្តោះអាសន្ន

### កថាភាគទី១ ល័ក្ខខ័ណ្ឌលើសិទ្ធិដែលត្រូវរក្សាការពារ

សិទ្ធិដែលត្រូវរក្សាការពារដោយការរឹបអូសជាបណ្តោះអាសន្ន ចាំបាច់ត្រូវតែជាសិទ្ធិទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់ (សិទ្ធិទាមទារឲ្យសងជាប្រាក់)[៥៤]។ ចំពោះសិទ្ធិលើទ្រព្យសម្បត្តិ ប្រសិនបើចង់សម្រេចឲ្យសងជាប្រាក់ ក៏អាចសុំឲ្យចាត់ចែងរក្សាការពារតាមរយៈការរឹបអូសជាបណ្តោះអាសន្នដែរ។

សិទ្ធិទាមទារដែលត្រូវរក្សាការពារ អាចជាសិទ្ធិដែលជាប់និងល័ក្ខខណ្ឌ ឬ ពេលកំណត់[៥៥] បាន ប៉ុន្តែចំពោះសិទ្ធិទាមទារដែលភ្ជាប់និងល័ក្ខខ័ណ្ឌបង្អង់ ចាំបាច់មានអត្ថិភាព មូលដ្ឋាននៃសិទ្ធិ។

<u>ឧទាហរណ៍</u> ៖ ដូចជា សិទ្ធិទាមទារឲ្យសងសំណង នាពេលអនាគតរបស់អ្នកធានា និង សិទ្ធិអ្នកដាក់ពាក្យបណ្តឹង ក្នុងការទាមទារឲ្យសងវិញនូវប្រាក់ប្រដាប់ក្តីនាពេលអនាគត ចំពោះភាគីម្ខាងទៀត។ ក៏ប៉ុន្តែ ចំពោះសិទ្ធិទាមទារដែលពុំមានការទទួលស្គាល់តម្លៃជាទ្រព្យសម្បត្តិបច្ចុប្បន្ន ដូចជាករណី ដែលល័ក្ខខ័ណ្ឌរបស់វាកម្រនឹងអាចសម្រេច ឬ ករណីដែល ពេលកំណត់ស្ថិតនៅឆ្ងាយពេក ជាដើមនោះ មិនអាចត្រូវបាន ទទួលស្គាល់នូវល័ក្ខខ័ណ្ឌនៃសិទ្ធិដែលត្រូវបានរក្សាការពារទេ។

ទោះបីជាបណ្តឹងអង្គសេចក្តីអំពីសិទ្ធិដែលមានការពាក់ព័ន្ធនោះ មិនអាចដាក់ទៅតុលាការកម្ពុជាបានដូចជាករណីនៃសិទ្ធិទាមទារដែលភ្ជាប់នឹងកិច្ចសន្យាមជ្ឈត្តកម្ម ឬ សិទ្ធិទាមទារដែលស្ថិតក្រោមសិទ្ធិជម្រះក្តីរបស់តុលាការបរទេស ជាអាទិ៍ក៏ដោយ ក៏អាចធ្វើការរឹបអូសជាបណ្តោះអាសន្នបានដែរ ដោយយោងទៅលើភាពចាំបាច់នៃការរក្សារការពារ។ ចំពោះសិទ្ធិទាមទារដែលកើតចេញពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង ការទាមទារឲ្យផ្តល់អាហារកាតព្វកិច្ច។ ការទាមទារឲ្យបែងចែកទ្រព្យសម្បត្តិ ក៏ត្រូវតែអនុវត្តដូចគ្នាដែរ។

### កថាភាគទី២ ភាពចាំបាច់នៃការរក្សារការពារ

ការចេញដីការសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវផ្អែកមិនត្រឹមតែទៅលើអត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សារការពារប៉ុណ្ណោះទេ តែត្រូវផ្អែកទៅលើភាពចាំបាច់នៃការរក្សារការពារផងដែរ។ មានន័យថា មានតែក្នុងករណីដែលការអនុវត្តដោយបង្ខំនាពេលអនាគត នឹងមិនអាចធ្វើបាន ឬ នឹងមានការ

---

[៥៤] មាត្រា ៥៣១ ចំណុចក និងមាត្រា ៥៤៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៥៥] មាត្រា ៥៤៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

លំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ បើបណ្តោយឲ្យស្ថានភាពបច្ចុប្បន្នស្ថិតនៅដដែល ប៉ុណ្ណោះទេ ដែលត្រូវចាត់ទុកថា ការរក្សាការពារមានភាពចាំបាច់។

ការរក្សាការពារ ត្រូវបានចាត់ទុកថាមានភាពចាំបាច់ នៅក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុល ទំនងជានឹងធ្លាក់តម្លៃជាបរិមាណ ឬ ជាគុណភាព ឬ នឹងមានទ្រព្យសម្បត្តិដែលពិបាកប្តូរជា ប្រាក់នៅក្នុងការអនុវត្តដោយបង្ខំប៉ុណ្ណោះដែលនៅសល់ ដោយសារការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃ ថោក ការខូចខាត ការបំបាត់ ជាអាទិ៍។ ការរក្សារការពារ ក៏ត្រូវបានចាត់ទុកថាមានភាពចាំបាច់ដែរ នៅក្នុងករណីដែលកូនបំណុលបានគេចខ្លួន ឬ បានប្តូរលំនៅឋានជាច្រើនលើកច្រើនសារ ហើយបើការណ៍នោះ ត្រូវបានយល់ឃើញថាជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំ។ ការកំណត់នេះមិនត្រូវកម្រិតតែត្រឹមអ្វីដែលផ្អែក លើទង្វើផ្ទាល់ខ្លួនរបស់កូនបំណុលតែប៉ុណ្ណោះទេ។ ក៏ប៉ុន្តែ ដោយសារថាគោលបំណងនៃការរឹបអូសជាបណ្តោះអាសន្ន មិនមែនដើម្បីទទួលបានការសម្រេចសិទ្ធិដែលពេញលេញមានភាពចាំបាច់ទេ។ ដោយឡែក ដោយងាយស្រួលនោះ ភាពចាំបាច់នៃការរក្សារការពារ នឹងត្រូវបានបដិសេធ។ ការបដិសេធរបស់កូនបំណុល ចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ ឬ ឥរិយាបថរបស់កូនបំណុលក្នុងការមិនព្រមអនុវត្តកាតព្វកិច្ច ចំពោះសិទ្ធិនោះ ពុំមែនជាមូលហេតុនៃការបញ្ជាក់អំពីភាពចាំបាច់នៃការរក្សារការពារទេ ព្រោះសកម្មភាពទាំង នោះមិនមែនជាឧបសគ្គ ចំពោះការអនុវត្តដោយបង្ខំឡើយ។ ត្រង់ចំណុចនេះ ចរិតលក្ខណៈរបស់ភាពចាំបាច់ក្នុងការរក្សារការពារ គឺខុសគ្នាពី «ភាពចាំបាច់ដែលតម្រូវឲ្យធ្វើការទាមទារជាមុន» ដែលជាល័ក្ខខ័ណ្ឌសម្រាប់ធ្វើបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលអនាគត។

ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំ ទំនងជានឹងត្រូវធ្វើនៅបរទេស នោះការរក្សារការពារ ត្រូវចាត់ទុកថាមានភាពចាំបាច់។

<u>ឧទាហរណ៍</u> ៖ ករណីដែលកូនបំណុលបានបង្ហាញសញ្ញានៃការចាត់ចែងទ្រព្យសម្បត្តិ និង ការធ្វើអន្តោប្រវេសន៍នៅបរទេស ជាអាទិ៍។

ទោះបីជាក្នុងករណីដែលបានបំពេញតាមល័ក្ខខ័ណ្ឌទូទៅហើយក៏ដោយ ក៏ភាពចាំបាច់នៃការរក្សាការពារ អាចនឹងត្រូវបានបដិសេធដែរ។

<u>ឧទាហរណ៍</u> ៖ ករណីដែលសិទ្ធិលើបំណុល មានភ្ជាប់នឹងសិទ្ធិប្រាតិភោគប្រត្យក្សគ្រប់គ្រាន់ហើយ ឬករណីដែលសិទ្ធិលើបំណុល បំពេញល័ក្ខខ័ណ្ឌគ្រប់គ្រាន់ដើម្បីធ្វើការអនុវត្ត ដោយបង្ខំ ដោយគ្មានល័ក្ខខ័ណ្ឌ។

## ផ្នែកទី២ ដីការសម្រេចរឹបអូសជាបណ្តោះអាសន្ន

**កថាភាគទី១ តុលាការនៃ ការរឹបអូសជាបណ្ដោះអាសន្ន**

តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ស្ថិតនៅ គឺជាតុលាការមានសមត្ថកិច្ចលើរឿងក្ដីនៃការរឹបអូសជាបណ្ដោះអាសន្ន[៥៦]។ សមត្ថកិច្ចនេះ គឺជាសមត្ថកិច្ចផ្ដាច់មុខ[៥៧]។

តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី ៖ «អង្គសេចក្ដី» គឺជារឿងក្ដីនៃបណ្ដឹងដែលពាក្យបណ្ដឹងត្រូវបានដាក់ ចំពោះសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ ជាករណីលើកលែង ដូចបានពន្យល់នៅខាងលើ អង្គសេចក្ដីក៏អាចជារឿងក្ដីមជ្ឈត្តកម្ម ឬ រឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងដែរ។ នៅមុនពេលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី តុលាការមានសមត្ថកិច្ច គឺតុលាការដែលមានសមត្ថកិច្ចលើរឿងក្ដីនៃបណ្ដឹងដែលនិងធ្វើនាពេលអនាគត ហើយបើមានតុលាការ ដែលមានសមត្ថកិច្ចបែបនេះច្រើន នោះអាចជ្រើសយកតុលាការណាមួយក្នុងចំណោមតុលាការទាំងនោះបាន។ នៅពេលដែលអង្គសេចក្ដីកំពុងត្រូវបានចាត់ការ ជាគោលការណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី គឺតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍[៥៨]។ ក្នុងករណីដែលអង្គសេចក្ដីកំពុងត្រូវបានចាត់ការនៅក្នុងនីតិវិធីនៃបណ្ដឹងសារទុក្ខនោះត្រូវត្រឡប់ទៅរកគោលការណ៍ដើមវិញ ពោល គឺតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី គឺតុលាការនៃការជំនុំជម្រះលើកទី១។

សាលាដំបូង ដែលមានសមត្ថកិច្ចលើទីកន្លែងដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ស្ថិតនៅ ៖ នៅក្នុងពាក្យសុំអោយចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន បើវត្ថុដែលជាកម្មវត្ថុនៃ ការរឹបអូស ជាបណ្ដោះអាសន្ន គឺជាវត្ថុក្រៅពីចលនវត្ថុ នោះត្រូវបញ្ជាក់អំពីវត្ថុដែលជាកម្មវត្ថុនោះ ហើយបើវត្ថុដែលជាកម្មវត្ថុ នៃការរឹបអូសជាបណ្ដោះអាសន្ន គឺជាចលនវត្ថុវិញ ត្រូវបញ្ជាក់អំពីទីកន្លែងនៃចលនវត្ថុនោះ។ ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន គឺជាសិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវចាត់ទុកថាសិទ្ធិនោះ ស្ថិតនៅឯលំនៅឋានរបស់កូនបំណុលទី៣ ឬ បុគ្គលដែលមានលក្ខណៈដូចជាកូនបំណុលទី៣។

**កថាភាគទី២ ពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**

ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ ៖ ពាក្យឲ្យសុំដីការសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ[៥៩]។ គោលបំណងនៃការកំណត់បែបនេះ គឺដើម្បីធានានូវភាពច្បាស់លាស់។ ពន្ធ

[៥៦] មាត្រា ៥៤០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៥៧] មាត្រា ៥៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៥៨] មាត្រា ៥៤០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៥៩] មាត្រា ៥៣៤ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

នៃការដាក់ពាក្យសុំ ត្រូវបានកំណត់ចំនួន ៥០០០ រៀល[៦០]។ ពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវសរសេរបញ្ជាក់នូវចំណុចដូច ខាងក្រោម ៖

ក. អត្តសញ្ញាណនៃភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់

ខ. ខ្លឹមសារនៃដីកាសម្រេចរក្សារការពារដែលអ្នកដាក់ពាក្យសុំទាមទារ

ជាគោលការណ៍ កម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន ត្រូវកំណត់អោយបានជាក់លាក់។ ក៏ប៉ុន្តែក្នុងករណីដែលកម្មវត្ថុនោះគឺជាចលនវត្ថុ មិនចាំបាច់កំណត់ជាក់លាក់អំពីចលនវត្ថុនីមួយៗនោះទេ តែត្រូវបញ្ជាក់អំពីទីកន្លែងនៃចលនវត្ថុនោះ។

គ. សិទ្ធិដែលត្រូវបានរក្សាការពារ ៖ ត្រូវរៀបរាប់អំពីមូលហេតុ និងចំនួនទឹកប្រាក់នៃសិទ្ធិទាមទារ ។

ឃ. ភាពចាំបាច់នៃការចាត់ចែងរក្សារការពារ៖ ចំពោះចំណុច គ និង ចំណុច ឃ ត្រូវសរសេរឲ្យបានច្បាស់លាស់ និងត្រូវសរសេរនូវភស្តុតាង តាមហេតុនីមួយៗដែលត្រូវបញ្ជាក់ ។

ង. ឯកសារនៃសេចក្ដីបញ្ជាក់ដំបូង ៖ ចំពោះចំណុច គ និងចំណុច ឃ ដោយសារថាអ្នកដាក់ពាក្យសុំ ត្រូវធ្វើសេចក្ដីបញ្ជាក់ ដំបូងដូច្នេះអ្នកដាក់ពាក្យសុំ ត្រូវភ្ជាប់ ជាមួយនិង ពាក្យសុំជាលាយលក្ខណ៍អក្សរនូវឯកសារ ដើម្បីធ្វើសេចក្ដីបញ្ជាក់ដំបូង។ ម្យ៉ាងទៀតអ្នកតំណាងដោយអាណត្តិដែលមានសិទ្ធិតំណាងនៅក្នុងបណ្ដឹងអំពីសិទ្ធិដែលត្រូវរក្សាការពារ ក៏ត្រូវមានសិទ្ធិតំណាងនៅក្នុងការដាក់ពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដែរ[៦១]។

### កថាភាគទី៣ វិធីនៃការវិនិច្ឆ័យ

នីតិវិធីនៃដីកាសម្រេច ៖ ដោយសារថា ការសម្រេចសេចក្ដីដែលទាក់ទងនឹងនីតិវិធីនៃដីការសម្រេចរក្សាការពារ ត្រូវធ្វើឡើង ដោយដីកាសម្រេច ដូច្នេះ នីតិវិធីនេះ មិនធ្វើតាមនីតិវិធីនៃបណ្ដឹងទេ គឺត្រូវធ្វើតាម នីតិវិធីនៃការចេញដីកាសម្រេច។ ហេតុនេះហើយ ការទាញហេតុផលដោយផ្ទាល់មាត់ មិនមានភាពចាំបាច់ជានិច្ចនោះទេ ពោលគឺតុលាការត្រូវកំណត់ថា ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ មិនត្រូវធ្វើ។ តុលាការអាចសួរភាគីបាន[៦២]។ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដែលទាមទារឲ្យធ្វើឡើងជាសម្ងាត់ ជាទូទៅត្រូវបានចេញ ដោយគ្រាន់តែសួរម្ចាស់បំណុលប៉ុណ្ណោះ។

ការធ្វើសេចក្ដីបញ្ជាក់ដំបូង ៖ ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តម្រូវឲ្យមានអត្ថិភាព នៃសិទ្ធិដែលត្រូវបានរក្សាការពារ និង ភាពចាំបាច់នៃការចាត់ចែងរក្សាការពារ។ ហេតុនេះ

---

[៦០] មាត្រា ៥៣៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៦១] មាត្រា ៥៤១ កថាខណ្ឌទី២ និងមាត្រា ៥៤១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៦២] មាត្រា ១១៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២និងមាត្រា ១១៤ កថាខណ្ឌទី២នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

ហើយចាំបាច់ត្រូវធ្វើសេចក្តីដំបូងអំពីចំណុចទាំងនេះ។ ប្រសិនបើគម្រូវឲ្យបញ្ជាក់តែម្តង នោះវាមិនមានអ្វីខុសគ្នាអំពីបណ្តឹងអង្គសេចក្តីនោះទេ ហើយក៏វាមិនស្របទៅនឹងភាពបណ្តោះអាសន្ន និង ភាពឆាប់រហ័សនៃការរឹបអូសជាបណ្តោះអាសន្នផងដែរ។ ចំពោះការធ្វើសេចក្តីបញ្ជាក់ដំបូង ត្រូវយកបញ្ញត្តិនៃមាត្រា ១៣១ មកអនុវត្ត។ មានន័យថាសេចក្តីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន។ ហេតុនេះហើយ ការប្រគល់កិច្ចការស្រាវជ្រាវ ការចេញដីកាសម្រេចបង្គាប់ឲ្យផ្តល់ឯកសារ ឬ ការសាកសួរសាក្សីដែលទាមទារឲ្យមានការកោះហៅមិនអាចធ្វើបានទេ។

**កថាភាគទី៤ ដីកាសម្រេច**

ការសម្រេចសេចក្តីលើពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើឡើងដោយដីកាសម្រេច[៦៣] ។

បើខ្វះល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការធ្វើបណ្តឹង ដែលអនុវត្តដូចគ្នាចំពោះនីតិវិធីនៃដីកាសម្រេចរក្សាការពារ (ដូចជាសមត្ថភាពភាគី និង លក្ខណៈសម្បត្តិជាភាគី) នោះពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន នឹងត្រូវបានលើកចោល។ បើខ្វះល័ក្ខខ័ណ្ឌទាមទារសម្រាប់ការរឹបអូសជាបណ្តោះអាសន្ន ក៏ពាក្យសុំនិងត្រូវបានលើកចោលដែរ (ជាទ្រឹស្តី វាគួរតែជាការច្រានចោល តែនៅទីនេះវាត្រូវបានចាត់ថែង ជាការលើកចោល)។ ចំពោះដីកាសម្រេចដែលលើកចោលពាក្យសុំនេះ អាចប្តឹងជំទាស់បាន អំឡុងពេលធម្មតានៃការប្តឹងជំទាស់ គឺ ១សប្តាហ៍ ប៉ុន្តែអំឡុងពេលនៃការប្តឹងជំទាស់នៅក្នុងករណីនេះ ត្រូវបានកំណត់ដល់ទៅ ២សប្តាហ៍ ដោយយោងទៅលើភាពស្មុគស្មាញរបស់វា[៦៤]។

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ៖ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវចេញនៅពេលដែលល័ក្ខខ័ណ្ឌទាមទារសម្រាប់ការរឹបអូសជាបណ្តោះអាសន្ន ក៏ដូចជាល័ក្ខខ័ណ្ឌចាំបាច់ផ្សេងទៀត សម្រាប់ការធ្វើបណ្តឹង ត្រូវបានបំពេញសព្វគ្រប់។ ជាគោលការណ៍ តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ។ ប៉ុន្តែ ចំពោះដីកាសម្រេចរឹបអូសចលនវត្ថុជាបណ្តោះអាសន្ន អាចចេញបានដោយមិនចាំបាច់កំណត់កម្មវត្ថុទេ។ តុលាការត្រូវបញ្ជូនដីកាសម្រេច រឹបអូសជាបណ្តោះអាសន្នទៅភាគី។ ការឲ្យដាក់ប្រាតិភោគ ឬ មិនឲ្យដាក់ប្រាតិភោគ ត្រូវអាស្រ័យ ទៅតាមឆន្ទានុសិទ្ធិរបស់តុលាការ នៅក្នុងការរឹបអូសជាបណ្តោះអាសន្ន ជាធម្មតា តែងតែមានការតម្រូវឲ្យដាក់ប្រាតិភោគ។ ប្រាតិភោគនេះ គឺដើម្បីធានានូវសំណងនៃការ ខូចខាតដែលអាច និងកើត

---

[៦៣] មាត្រា ៥៣៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

[៦៤] មាត្រា ៥៤៤ និង មាត្រា ៣០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

មានដល់កូនបំណុល ក្នុងករណីដែលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននេះ មានភាពខុសពីការពិត[៦៥]។

ឧទាហរណ៍ ៖ ករណីដែលកម្មវត្ថុមិនអាលក់បានដោយសាការរឹបអូសជាបណ្ដោះអាសន្ន ហើយនៅពេលដែល អាចលក់វិញថ្លៃរបស់វាបានធ្លាក់ចុះ។ ម្យ៉ាងទៀត ជំនួសឲ្យការបង្គាប់ឲ្យដាក់ប្រាតិភោគជាមុនតុលាការក៏អាចបង្គាប់ឲ្យដាក់ប្រាតិភោគគឺត្រូវធ្វើតាមវិធីផ្ញើរប្រាក់ ឬ ឧបករណ៍អាចជួញដូរបានដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឲ្យដាក់ប្រាតិភោគ[៦៦] ។

ចំពោះការប្ដូរប្រាតិភោគ និង ចំពោះសិទ្ធិរបស់អ្នកដែលទទួលការប្រាតិភោគ និង ការលុបចោលនូវប្រាតិភោគ ត្រូវយកបញ្ញត្តិស្ដីពី ប្រាតិភោគលើបណ្ដឹង មកអនុវត្ត។ ចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដែលបង្គាប់ឲ្យដាក់ប្រាតិភោគ ម្ចាស់បំណុលដែលអះអាងថាដីការសម្រេចនោះគួរចេញដោយមិនចាំបាច់ឲ្យដាក់ប្រាតិភោគ អាចប្ដឹងជំទាស់បាន ដីកាសម្រេចនេះអាចចាត់ទុកថាជាការលើកចោលពាក្យសុំមួយផ្នែក[៦៧] ។

ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន ៖ ក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នតុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើទៅតុលាការ ដើម្បទទួលបានការលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន មានគោលបំណងរក្សាការពារនូវការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់ ហេតុដូច្នេះ ប្រសិនបើចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់នៃសិទ្ធិទាមទារដែលពាក់ព័ន្ធត្រូវបានផ្ញើ ម្ចាស់បំណុលនិងមិនទទួលការខូចខាតទេ។ ម្យ៉ាងទៀត វាអាចនឹងនាំឲ្យមានការបាត់បង់ផលប្រយោជន៍មួយចំនួនដល់កូនបំណុល ប្រសិនបើកូនបំណុលត្រូវបានហាមឃាត់ ក្នុងការចាត់ចែងទ្រព្យសម្បត្តិ ដោយសារការអនុវត្តរឹបអូសជាបណ្ដោះអាសន្ននោះ។ ហេតុនេះហើយបានជាច្បាប់អនុញ្ញាតឲ្យមានការរំដោះខ្លួន ចេញពីការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ដោយផ្ញើប្រាក់ដែលស្មើនឹងចំនួនទឹកប្រាក់នៃសិទ្ធិទាមទារ។ ប្រាក់ដែលផ្ញើនេះ នឹងជំនួសឲ្យទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន ហើយនៅពេលដែលម្ចាស់បំណុលបានទទួលលិខិតអនុវត្តហើយ ម្ចាស់បំណុលនោះអាចរឹបអូសសិទ្ធិទាមទារ ឲ្យប្រគល់ប្រាក់ដែលផ្ញើបាន ។

## ផ្នែកទី៣ ឧបាស្រ័យចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

### កថាភាគទី១ ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

[៦៥] មាត្រា ៥៤៦ និងមាត្រា ៥៤៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

[៦៦] មាត្រា ៥៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

[៦៧] មាត្រា៧១ កថាខណ្ឌទី២ និងមាត្រា ៧២ និង៧៣ រួមទាំងមាត្រា ៥៤៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

ចំពោះដីកាសម្រេចរក្សាការពារ មិនអាចប្តឹងជំទាស់ភ្លាមបានទេ ប៉ុន្តែ អាចដាក់ពាក្យសុំតវ៉ា ទៅតុលាការដែលបានចេញដីកាសម្រេចនោះបាន[៦៨]។ ការដាក់ពាក្យសុំតវ៉ា គឺជាឱកាសដែលផ្តល់ ឲ្យកូនបំណុលដែលពុំមានឱកាសចូលរួមនៅក្នុងនីតិវិធីជាមុន ក្នុងការសុំឲ្យមានការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវ នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មិនមែនដោយតុលាការជាន់ខ្ពស់ទេ តែដោយតុលាការថ្នាក់ដដែល ដែលចំណុចនេះស្រដៀងគ្នាទៅនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿន នៅក្នុងនីតិវិធីនៃការដាស់តឿនដែរ។ ក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់ លុបចោលដីកាសម្រេចលើកចោល ពាក្យស្នើសុំតវ៉ា ចំពោះដីកាសម្រេចនេះ ត្រូវដាក់ទៅតុលាការនៃបណ្តឹងជំទាស់នោះដែរ។

ពាក្យសុំតវ៉ា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ ដោយពុំមានការកំណត់អំឡុងពេល ពាក្យសុំតវ៉ាអាចដាក់នៅពេលណាក៏បានឲ្យតែដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននៅមានសុពលភាព។ ការដាក់ពាក្យសុំតវ៉ា មិនធ្វើឲ្យអានុភាពអនុវត្ត នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ផ្អាកដោយស្វ័យប្រវត្តិទេ គឺត្រូវមានសេចក្តីសម្រេចបណ្តោះអាសន្នដោយឡែក ដែលបង្គាប់ឲ្យផ្អាកការអនុវត្តរក្សាការពារ ឬ លុបចោលការតុបតែងការអនុវត្ត។ សេចក្តីសម្រេចបណ្តោះអាសន្ននេះ អាចធ្វើបានតែក្នុងករណី ដែលមានសេចក្តីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ និង អំពីការដែលមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយសារការអនុវត្តការរក្សាការពារនោះប៉ុណ្ណោះ ហើយម្យ៉ាងទៀត ការដាក់ប្រាតិភោគ មានភាពចាំបាច់ជានិច្ច[៦៩]។ ស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ សំដៅទៅលើស្ថានភាព ដែលផ្ទុយយ៉ាងច្បាស់លាស់នឹងអត្ថិភាព នៃសិទ្ធិដែលត្រូវបានរក្សាការពារ និង ភាពចាំបាច់នៃការចាត់ចែងរក្សាការពារ ដែលជាល័ក្ខខណ្ឌចាំបាច់សម្រាប់ការចេញដីកាបណ្តោះអាសន្ន។

<u>ឧទាហរណ៍</u> ៖ មានភាពមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែតនៅក្នុងការទទួលស្គាល់ ឬ នៅក្នុងការបកស្រាយច្បាប់។ ដោយឡែក ការបារម្ភថាការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយសារការអនុវត្តការរក្សាការពារ សំដៅទៅលើករណីដែលសំណងជាប្រាក់ តាមក្រោយទំនងជា និង មិនអាចសងគ្រប់ចំពោះការខូចខាតរបស់កូនបំណុលបានឡើយ។

<u>ឧទាហរណ៍</u> ៖ ករណីដែលកូនបំណុលនឹងក្ស័យធន ឬមិនអាចរស់បាន ដោយសារការអនុវត្តការរឹបអូសជាបណ្តោះអាសន្ននូវប្រាក់បញ្ញើនៅធនាគាររបស់កូនបំណុល។

---

[៦៨] មាត្រា ៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៦៩] មាត្រា ៥៣៤ និង មាត្រា ៥៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

នៅក្នុងការវិនិច្ឆ័យក្នុងការតវ៉ា តុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន[៧០]។ គោលបំណងនៃការកំណត់បែបនេះគឺដើម្បីផ្តល់ទៅឲ្យភាគី (ជាពិសេសកូនបំណុល) នូវការធានានៅក្នុងការចូលរួមក្នុងនីតិវិធី។ ប៉ុន្តែ យ៉ាងណាក៏ដោយ វាមិនចាំបាច់ទាល់តែថា នៅក្នុងកាលបរិច្ឆេទទាំងអស់ ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរដែលភាគីទាំងសងខាងអាចចូលរួមបាននោះទេ គឺគ្រាន់តែធានាអោយបាននូវកាលបរិច្ឆេទដែល ភាគីទាំងសងខាងអាចចូលរួមបាន តែម្តងក៏ជាការគ្រប់គ្រាន់ដែរ។ ដើម្បីបញ្ជាក់ការវិនិច្ឆ័យអំពីការតវ៉ា ជាគោលការណ៍ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ[៧១]។ ទោះបីជាទូទៅ នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេច តុលាការអាចបញ្ចប់ការវិនិច្ឆ័យរបស់ខ្លួននៅពេលណាក៏បាន ក៏ដោយ ក៏នៅក្នុងនីតិវិធីនៃការវិនិច្ឆ័យអំពីការតវ៉ានេះ តុលាការត្រូវជូនដំណឹងទៅភាគី អំពីកាលបរិច្ឆេទនៃការបញ្ចប់ការនិវិច្ឆ័យ ដើម្បីផ្តល់ឱកាសឲ្យភាគី ក្នុងការដាក់ឯកសារសម្រាប់ការវិនិច្ឆ័យ ទៅតុលាការ ឲ្យបានគ្រប់គ្រាន់។ ក៏ប៉ុន្តែ ប្រសិនបើការនិវិច្ឆ័យត្រូវបញ្ចប់នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗ ថាបញ្ចប់ការវិនិច្ឆ័យបាន ព្រោះថាការធានានៅក្នុងនីតិវិធីត្រូវបានផ្តល់ឲ្យបានគ្រប់គ្រាន់ហើយ គឺដូចគ្នាទៅនិងនីតិវិធីបណ្តឹងដែរ[៧២]។

នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ា តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬ លុបចោលនូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ប្រសិនបើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មានភាពត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចទទួលស្គាល់ដីកាសម្រេចនោះ។ រីឯតុលាការត្រូវចេញដីកាសម្រេចផ្លាស់ប្តូរ។ ករណីនេះរួមបញ្ចូល ករណីដូចជាល័ក្ខខណ្ឌ ដែលម្ចាស់បំណុលត្រូវដាក់ប្រាតិភោគ ឬការបន្ថែមនូវប្រាតិភោគ នៅក្នុងអំឡុងពេលកំណត់ណាមួយ ជាអាទិ៍។ តុលាការត្រូវចេញដីកាសម្រេចលុបចោលការរឹបអូសជាបណ្តោះអាសន្ន ប្រសិនបើដីកាសម្រេចនោះ មានភាពមិនត្រឹមត្រូវ ហើយនៅក្នុងករណីនេះ មិនមានអានុភាព បើមិនទាន់ចូលជាស្ថាពរទេ ក៏ប៉ុន្តែ បើយល់ឃើញថាចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនេះមានអានុភាពភ្លាមៗបាន។ ដីកាសម្រេចទាំងនេះត្រូវបញ្ជូនទៅអោយភាគី ហើយបណ្តឹងជំទាស់អាចធ្វើបានចំពោះដីកាសម្រេចទាំងនេះ[៧៣]។

**កថាភាគទី២ ការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

[៧០] មាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៧១] មាត្រា ៥៥៣ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៧២] មាត្រា ៥៥៣ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៧៣] មាត្រា៥៥៤ កថាខណ្ឌទី ១ និងមាត្រា៥៥៦ និងមាត្រា៥៦១ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

ក្រៅពីការលុបចោលដោយសារការតវ៉ា ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អាចត្រូវបានលុបចោលនៅក្នុងករណីពីរទៀត ដែលមាននីតិវិធីដោយឡែកពីគ្នា តាមពាក្យសុំរបស់កូនបំណុល ការលុបចោលដោយសារការមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី និង ការលុបចោលដោយសារការផ្លាស់ប្ដូរស្ថានភាព។

ការលុបចោល ដោយសារការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវបង្គាប់ឲ្យម្ចាស់បំណុល ដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ដោយឲ្យដាក់ ឯកសារដែលបញ្ជាក់ពីការដាក់ពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យតាមពាក្យសុំរបស់កូនបំណុល។ ការបង្គាប់នេះ ហៅថា ការបង្គាប់ឲ្យដាក់ពាក្យបណ្ដឹង។ គោលបំណងនៃការបង្គាប់នេះ គឺដើម្បីបង្ខំអោយម្ចាស់បំណុលទៅទទួលលិខិតអនុវត្ត សម្រាប់ការអនុវត្តដោយបង្ខំចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ។ ការកំណត់បែបនេះនឹងទប់ស្កាត់នូវការខូចខាតធ្ងន់ធ្ងរដែលអាចនឹងកើតមានដល់កូនបំណុល ដោយសារទុកស្ថានភាព ដែលមានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឲ្យយូរអង្វែង។ ហេតុនេះហើយ ការបង្គាប់ឲ្យដាក់ពាក្យបណ្ដឹង អាចចេញបានដោយពុំមានល័ក្ខខណ្ឌ ទាមទារអ្វីទេ ប្រសិនបើមានពាក្យសុំរបស់កូនបំណុល។ អំឡុងពេលនៃការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី មិនត្រូវតិចជាង២សប្ដាហ៍ទេ[៧៤] ។

ប្រសិនបើម្ចាស់បំណុល មិនដាក់ឯកសារ បញ្ជាក់ជាលាយលក្ខណ៍អក្សរ អំពីការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី នៅក្នុងអំឡុងពេល ដែលបានកំណត់នៅក្នុងការបង្គាប់ឲ្យដាក់ពាក្យបណ្ដឹងទេ តុលាការត្រូវលុបចោល ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នតាមពាក្យសុំរបស់កូនបំណុល។ ម្យ៉ាងទៀតប្រសិនបើនៅក្រោយពេលដាក់ឯកសារបញ្ជាក់នេះហើយ ពាក្យបណ្ដឹងអង្គសេចក្ដីត្រូវបានដកវិញ ឬ ត្រូវបានលើកចោល នោះត្រូវចាត់ទុកថា ឯកសារនេះមិនបានដាក់ឡើយ ហើយការនោះក៏នឹងនាំទៅដល់ការចេញដីកាសម្រេចលុបចោលផងដែរ។ ការចាប់ផ្ដើមនីតិវិធីមជ្ឈត្តកម្ម ប្រសិនបើមានកិច្ចសន្យាមជ្ឈត្តកម្ម អំពីអង្គសេចក្ដី និង ការចាប់ផ្ដើមនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងក៏ត្រូវចាត់ទុកថាជាការដាក់ពាក្យបណ្ដឹងអង្គសេចក្ដីដែរ។ ដីកាសម្រេចលុបចោល ត្រូវបញ្ជូនទៅភាគី ហើយបណ្ដឹងជំទាស់អាចធ្វើបានចំពោះដីកាសម្រេចនេះ[៧៥]។

ការលុបចោលដោយសារការផ្លាស់ប្ដូរស្ថានភាព បើមានការ រំលត់សិទ្ធិដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្ដូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីការសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដី អាចលុបចោលដីកា

[៧៤] មាត្រា ៥៥៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៧៥] មាត្រា ៥៥៧ កថាខណ្ឌទី ៣,៤,៥.៨ និងមាត្រា ៥៦១ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

សម្រេចរឹបអូសជាបណ្ដោះអាសន្ន តាមពាក្យសុំរបស់កូនបំណុលបាន[៧៦]។ ការផ្លាស់ប្ដូរស្ថានភាពនេះ ត្រូវបានបែងចែកជាពីរប្រភេទ។ ប្រភេទទីមួយ គឺករណីដែលក្រោយពេលចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មានកើតឡើងនូវអង្គហេតុថ្មី ដែលធ្វើឲ្យដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននោះ មានភាពមិនត្រឹមត្រូវ។

ឧទាហរណ៍ ៖ ករណីដែលសិទ្ធិទាមទារទាំងអស់ដែលត្រូវបានរក្សាការពារ ត្រូវបានសងគ្រប់ចំនួន ករណីដែលមានសាលក្រមនៃការជំនុំជម្រះលើកទី ១ សម្រេចឲ្យម្ចាស់បំណុលចាញ់ក្ដី នៅក្នុងបណ្ដឹងអង្គសេចក្ដី ករណីដែលកូនបំណុលក្លាយជាអ្នកមានទ្រព្យសម្បត្តិគ្រប់គ្រាន់ដើម្បីសង ករណីដែលម្ចាស់បំណុលមិនធ្វើការ អនុវត្តដោយបង្ខំ បើទោះជាបានបំពេញគ្រប់ល័ក្ខខ័ណ្ឌទាមទារដែលអាចអនុវត្តដោយបង្ខំបានហើយក៏ដោយ ។ ប្រភេទទីពីរ គឺករណីដែលកូនបំណុលបានដឹងអំពីអង្គហេតុដែលនាំឲ្យដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននោះ មានភាពមិនត្រឹមត្រូវ ឬ អាចធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីហេតុនោះ នៅក្រោយពេលចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ទោះបីជាអង្គហេតុនោះបានកើតឡើងនៅពេលចេញដីកាសម្រេចរក្សាការពារក៏ដោយ។ នៅក្នុងករណីនេះ កូនបំណុលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង អំពីការផ្លាស់ប្ដូរស្ថានភាពនោះ[៧៧]។

បញ្ញត្តិទាក់ទងនឹងការសម្រេចសេចក្ដីអំពីការតវ៉ាចំពោះដីកាសម្រេចរឹបអូស ជាបណ្ដោះអាសន្ន ត្រូយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្ដីអំពីពាក្យសុំទាមទារឲ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។ មានន័យថា បញ្ញត្តិស្ដីពីការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ការទាញហេតុផលដោយផ្ទាល់មាត់ និង ការសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន ការបញ្ចប់ការវិនិច្ឆ័យ និង អនុភាពនៃដីកាសម្រេចលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយសារការផ្លាស់ប្ដូរស្ថានភាព។ ដីការសម្រេចលុបចោល អាចដាក់ល័ក្ខខណ្ឌឲ្យកូនបំណុលដាក់ប្រាតិភោគបាន ហើយដីកាសម្រេចនេះ ត្រូវបញ្ជូនទៅភាគី និង អាចប្ដឹងជំទាស់បាន[៧៨]។

### កថាភាគទី៣ បណ្ដឹងជំទាស់

ដូចពន្យល់រួចហើយ ចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មិនអាចប្ដឹងជំទាស់បានទេ។ ក៏ប៉ុន្តែ ចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ ពាក្យសុំទាមទារឲ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អាចប្ដឹងជំទាស់បាន។ បញ្ញត្តិនេះ ធានា

---

[៧៦] មាត្រា ៥៥៨ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៧៧] មាត្រា ៥៥៨ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៧៨] មាត្រា៥៦០, ៥៥១, ៥៥២, ៥៥៣, ៥៥៨, និងមាត្រា ៥៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

ចំពោះការសម្រេចសេចក្តីអំពីការរឹបអូសជាបណ្តោះអាសន្នផងដែរ នូវឱកាសក្នុងការទទួលបានការវិនិច្ឆ័យ និងការសម្រេចសេចក្តី នៅតុលាការជាន់ខ្ពស់។ ដីកាសម្រេចដែលទទួលស្គាល់ផ្លាស់ប្តូរ ឬលុបចោលការសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយផ្អែកលើពាក្យសុំតវ៉ា និង ដីការសម្រេចដែលលើកចោលពាក្យសុំទាមទារឲ្យលុបចោល ឬ ដែលលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយផ្អែកលើ ពាក្យសុំទាមទារឲ្យលុបចោល សុទ្ធសឹងជាមុខសញ្ញានៃការប្តឹងជំទាស់។ អំឡុងពេលនៃការប្តឹងជំទាស់ គឺ ២ សប្តាហ៍ ចាប់ពីថ្ងៃ ដែលបានទទួលការបញ្ជូន។

ក្នុងករណី ដែលតុលាការនៃបណ្តឹងជំទាស់ ចេញដីកាសម្រេចរឹបអូសជាបណ្តុះអាសន្នជាលើកទីមួយ បណ្តឹងជំទាស់មិនអាចធ្វើបានទេ ចំពោះដីកាសម្រេចនេះ ព្រោះមានការបកស្រាយថា ដីកាសម្រេចនេះ បានបំពេញល័ក្ខខ័ណ្ឌនៃប្រព័ន្ធនៃការជម្រះក្តីពីរថ្នាក់រួចហើយ។ ផ្ទុយទៅវិញក្នុងករណីដែលសាលាឧទ្ធរណ៍បានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និង លើកចោលពាក្យសុំតវ៉ា ឬពាក្យសុំទាមទារ ឲ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ នៅក្នុងបណ្តឹងអង្គសេចក្តីដែលកំពុងត្រូវបានចាត់ការនៅសាលាឧទ្ធរណ៍ នោះបណ្តឹងជំទាស់អាច ធ្វើទៅតុលាការកំពូលបានដើម្បីធានាឲ្យបាននូវប្រព័ន្ធនៃការជម្រះក្តីពីរថ្នាក់ ។

ជាមូលដ្ឋាន បញ្ញត្តិទាក់ទងនឹងការសម្រេចសេចក្តី និង ដីកាសម្រេច នៅតុលាការនៃការជំនុំជម្រះអំពីការតវ៉ា ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្តី និង ដីកាសម្រេច នៅតុលាការនៃបណ្តឹងជំទាស់។ ដូច្នេះ បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា រួមមានបញ្ញត្តិស្តីពីការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ការទាញហេតុផលដោយផ្ទាល់មាត់ និងការសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន ការបញ្ចប់ការវិនិច្ឆ័យ ដីកាសម្រេចលុបចោលដោយមានល័ក្ខខ័ណ្ឌឲ្យដាក់ប្រាតិភោគ ការបញ្ជូនដីកាសម្រេច ក្រៅពីនេះបញ្ញត្តិទូទៅស្តីពីបណ្តឹងជំទាស់ ក៏ត្រូវយកមកអនុវត្តផងដែរ លើកលែងតែមានបញ្ញត្តិពិសេស។

## ផ្នែកទី៤ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

### កថាភាគទី១ ល័ក្ខខ័ណ្ឌនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ភាពមិនចាំបាច់នៃរូបមន្តអនុវត្ត ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមានអានុភាព អនុវត្តភ្លាមនិងជាគោលការណ៍ត្រូវអនុវត្តបានភ្លាមៗដោយសារមានការកម្រិតអំឡុងពេលនៃការអនុវត្ត។ មានន័យថាអត្ថិភាពនៃអនុភាពអនុវត្ត មិនចាំបាច់ត្រូវធ្វើនិយ័តកម្ម ដោយរូបមន្តអនុវត្តទេ។ ហេតុនេះហើយ ជាគោលការណ៍ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូត នៃដីកាសម្រេចរក្សាការពារ។ ក៏ប៉ុន្តែ ប្រសិនបើការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានអនុវត្តចំពោះជនក្រៅពីភាគី ឬ សម្រាប់ជនក្រៅពីភាគីដែលបានកំណត់នៅក្នុងដីកាសម្រេចរឹបអូសជា

បណ្តោះអាសន្ន នោះដើម្បីបញ្ជាក់ភាគីនៃការអនុវត្ត។ ការអនុវត្តនេះ ទាមទារឲ្យមានការផ្តល់នូវរូបមន្ត អនុវត្ត (រូបមន្តអនុវត្តពិសេស)[៧៩] ។

អំឡុងពេលនៃការអនុវត្ត ការរឹបអូសជាបណ្តោះអាសន្ន មិនអាចអនុវត្តបានទៀតឡើយ ប្រសិនបើ មិនបានអនុវត្តក្នុងកំឡុងពេល ២ សប្តាហ៍ គិតចាប់ពីថ្ងៃ ដែលដីកាសម្រេចរឹបអូសជាបណ្តោះ អាសន្ន ត្រូវបានបញ្ជូនទៅម្ចាស់បំណុល[៨០]។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថាប្រសិនបើមិន អនុវត្តភ្លាមៗទេ នោះការរឹបអូសជាបណ្តោះអាសន្ន នឹងមិនមានភាពចាំបាច់ឡើយ។ ក៏ប៉ុន្តែវាជាការគ្រប់ គ្រាន់ហើយក្នុងការចាប់ផ្តើមសកម្មភាពនៃការអនុវត្ត នៅក្នុងកំឡុងពេល ២ សប្តាហ៍ ចំណែកឯ សកម្មភាពបន្តបន្ទាប់មកទៀតនៃការអនុវត្ត មិនចាំបាច់ត្រូវតែធ្វើនៅក្នុងអំឡុងពេលនេះទេ។ អំឡុង ពេលនេះ មិនកែប្រែជាថ្មីដោយដីកាសម្រេចទទួលស្គាល់ការរឹបអូសជា បណ្តោះអាសន្ន ដែលបានចេញ ដោយសារមានការដាក់ពាក្យសុំតវ៉ានោះទេ។ ក៏ប៉ុន្តែ ក្នុងករណីដែលការអនុវត្តដីកាសម្រេចរឹបអូសជា បណ្តោះអាសន្ន ត្រូវបានផ្អាកនៅមុនពេលផុតអំឡុងពេលនេះ ត្រូវចាត់ទុកថា អំឡុងពេលមានដំណើរ ការពីដំបូង ចាប់ពីពេលដែលការផ្អាកបានកន្លងផុត។ ទោះបីជាអំឡុងពេលនោះកន្លងផុតក៏ដោយ ក៏មិន ធ្វើឲ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នបាត់បង់អានុភាពក៏ដោយ ក៏គេអាចធ្វើឧបាស្រ័យចំពោះ ការអនុវត្តនៅក្រោយពេលផុតអំឡុងពេល ដោយការដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត[៨១] ឬ ដោយ បណ្តឹងជំទាស់បានដែរ។

ការបញ្ជូនលិខិតអនុវត្ត ៖ ទោះបីនៅមុនពេលដែលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវ បានបញ្ជូនទៅកូនបំណុលក៏ដោយ ក៏ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន អាចធ្វើបានដែរ[៨២]។ បញ្ញត្តិ នេះ ត្រូវបានកំណត់ដោយផ្អែកទៅលើភាពឆាប់រហ័ស និង ភាពលាក់ការសម្ងាត់ដែលជាគោលបំណង នៃការចាត់ចែងរក្សាការពារ។

**កថាភាគទី២ ប្រភេទផ្សេងៗនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន**

ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ជាមូលដ្ឋាន ត្រូវធ្វើទៅតាមការអនុវត្តការរឹបអូស នៅក្នុង ករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឲ្យសងជាប្រាក់ដែរ។ ក៏ប៉ុន្តែ ជាគោលការណ៍ ការអនុ វត្តនេះមិនឈានចូលទៅដល់ដំណាក់កាលនៃការប្តូរជាប្រាក់ទេ។ នៅគ្រប់ករណីទាំងអស់ ការអនុវត្តរឹប

---

[៧៩] មាត្រា ៥៦២ កថាខណ្ឌទី ១ វាក្យខណ្ឌទី១ និង វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៨០] មាត្រា ៥៦២ កថាខណ្ឌទី ២ វាក្យខណ្ឌទី១ និង វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៨១] មាត្រា ៣៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៨២] មាត្រា ៥៦២ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

អូសជាបណ្តោះអាសន្ន ចាប់ផ្តើមដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុល ទៅស្ថាប័នអនុវត្ត ហើយពាក្យសុំនោះ ត្រូវធ្វើដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុល ទៅស្ថាប័នអនុវត្ត។

ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចំពោះចលនវត្ថុ ៖ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ត្រូវធ្វើឡើងតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ។ នីតិវិធីនេះជាមូលដ្ឋាន ត្រូវធ្វើតាមវិធីដូចគ្នាទៅនឹងការរឹបអូសនៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ។ ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺជាប្រាក់ អាជ្ញាសាលាមិនដកហូតទុក ឬ ទុកឲ្យកូនបំណុលរក្សាទុកប្រាក់នោះទេ តែអាជ្ញាសាលាត្រូវផ្ញើប្រាក់នោះ នៅតុលាការដែលខ្លួនស្ថិតនៅ[៨៣] ។

វត្ថុផ្សេងទៀតក្រៅពីប្រាក់ត្រូវដកហូត និង រក្សាទុកដោយអាជ្ញាសាលា។ ក៏ប៉ុន្តែ ប្រសិនបើមានការបារម្ភថា ចលនវត្ថុត្រូវបានរឹបអូសជាបណ្តោះអាសន្ននោះនឹងចុះតម្លៃយ៉ាងខ្លាំង ឬ បើត្រូវការសោហ៊ុយច្រើនហួសហេតុដើម្បីរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលាអាចលក់ចលនវត្ថុនោះ តាមនីតិវិធីនៃការលក់នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុបាន តាមពាក្យសុំរបស់ម្ចាស់បំណុល ឬ កូនបំណុល។ នៅក្នុងករណីនេះ ប្រាក់ដែលទទួលបានពីការលក់ ត្រូវយកទៅផ្ញើនៅតុលាការដែលអាជ្ញាសាលានោះស្ថិតនៅ។ មាត្រា៣៨៧ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវផ្ទុកផ្តាក់ឲ្យស្ថាប័នដែលមានសមត្ថកិច្ច សរសេរនូវហេតុការណ៍នៃការរឹបអូសជាបណ្តោះអាសន្ន ចូលទៅក្នុងសៀវភៅបញ្ជី ហើយការរឹបអូសជាបណ្តោះអាសន្ននោះ នឹងត្រូវមានអានុភាព នៅពេលដែលបានសរសេរចូលក្នុងសៀវភៅបញ្ជីនោះ។

ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត៖ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវធ្វើតាមរបៀបដែលតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចដែលហាមឃាត់មិនឲ្យកូនបំណុលទី ៣ សងទៅកូនបំណុល។ តុលាការដែលមានសមត្ថកិច្ច ជាតុលាការដែលអនុវត្តរក្សាការពារ គឺតុលាការ ដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ នីតិវិធីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ជាមូលដ្ឋាន មានលក្ខណៈដូចគ្នាទៅនឹងការរឹបអូស នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែរ[៨៤]។ នៅក្នុងករណីដែលការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់ ប្រសិនបើកូនបំណុលទី៣ បានផ្ញើប្រាក់ស្មើនិងចំនួនទឹកប្រាក់ទាំងអស់ ឬ មួយផ្នែកនៃ

[៨៣] មាត្រា ៥៦៥ មាត្រា ៣៨៤ និងបញ្ញត្តិចាប់ពីមាត្រា ៣៨៥ ដល់មាត្រា ៣៩២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៨៤] មាត្រា៥០៣ មាត្រា, ៥០៤, ៥០៨, ៥១១ និង មាត្រា៥១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

សិទ្ធិលើបំណុល នៅតុលាការ នោះនៅក្នុងចំនួន ទឹកប្រាក់ទាំងអស់ដែលបានផ្ញើ ភាគដែលស្មើនឹងប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ត្រូវចាត់ទុកថា ជាប្រាក់ដែលកូនបំណុលបានផ្ញើជាប្រាក់រំដោះ ហើយភាគដែលលើស ត្រូវចាត់ទុកថាជាការសងចំពោះកូនបំណុលនៃការអនុវត្ត។

ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុ ៖ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននោះ។ តុលាការដែលមានសមត្ថកិច្ច ជាតុលាការអនុវត្តរក្សាការពារ គឺតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ក្រឡាបញ្ជី ត្រូវផ្ទុកផ្តាក់ឲ្យស្ថាប័នដែលមានសមត្ថកិច្ច ចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន។ នីតិវិធីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ជាមូលដ្ឋានមានលក្ខណៈដូចគ្នាទៅនឹងការរឹបអូសនៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែរ[៨៥]។

**កថាភាគទី៣ ការផ្អាក និងការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន**

ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន អាចត្រូវបានផ្អាក ក្នុងលក្ខណៈជាការផ្អាកការអនុវត្តដោយសារមានពាក្យសុំតវ៉ា ឬ ពាក្យសុំទាមទារឲ្យលុបចោល នូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និងពាក្យបណ្តឹងជំទាស់ចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ា ឬ ពាក្យសុំលុបចោល ការផ្អាកការអនុវត្តដោយសារមានការតវ៉ាចំពោះការអនុវត្ត និង ដោយសារមានការដាក់ពាក្យបណ្តឹងជំទាស់[៨៦] ការផ្អាកការអនុវត្តដោយសារមានបណ្តឹងជំទាស់ជាអាទិ៍[៨៧]។ ប៉ុន្តែយ៉ាងណាក៏ដោយ ខុសប្លែកអំពីការអនុវត្តដោយបង្ខំ ការផ្អាកនៅក្រោយការអនុវត្ត មិនសូវមានអត្ថន័យទេ ព្រោះថាការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវបានបញ្ចប់នៅត្រឹមដំណាក់កាលនៃការរឹបអូសតែប៉ុណ្ណោះ។

ស្រដៀងគ្នាទៅនឹងករណីនៃការអនុវត្តដោយបង្ខំដែរ ការលុបចោលនូវការចាត់ចែងការអនុវត្តរឹបអូសជាបណ្តោះអាសន្ន អាចធ្វើទៅបាន[៨៨]។ បន្ថែមពីលើនេះ មានប្រព័ន្ធនៃការលុបចោលការចាត់ចែងការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ដោយការផ្ញើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន។ ទោះជាបណ្តឹងជំទាស់អាចធ្វើបានចំពោះដីកាសម្រេចសេចក្តីនេះ ការលុបចោលការអនុវត្ត ត្រូវមានអានុភាពភ្លាមៗ ដោយមិនបាច់ចាំរហូតដល់ពេលចូលជាស្ថាពរ[៨៩] ។

**កថាភាគទី៤ ការបំលែងពីការរឹបអូសបណ្តោះអាសន្ន ទៅជាការអនុវត្តដោយបង្ខំ**

---

[៨៥] មាត្រា ៥៦៧, ៤២០, ២៤១, ៤២៤, ៤២៥, ៤៦៥, ៤៦៦, ៤៥៤, ៤៦៦, ៤៥៤,នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៨៦] មាត្រា ៣៤៣ កថាខណ្ឌទី ២. មាត្រា ៣៤៤ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៨៧] មាត្រា ៣៦៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៨៨] មាត្រា ៣៦៧ កថាខណ្ឌទី២. មាត្រា ៣៧០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

[៨៩] មាត្រា ៥៦៩ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

នៅក្រោយពេលដែលការរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានអនុវត្ត ប្រសិនបើគ្រប់ល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំ ត្រូវបានបំពេញ ហើយម្ចាស់បំណុលបានដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្ត នោះការរឹបអូសជាបណ្ដោះអាសន្ន ត្រូវបំលែងទៅជាការអនុវត្តដោយបង្ខំវិញ ត្រឹមទំហំនៃការអនុវត្តនោះ។ ហេតុនេះហើយ នីតិវិធីនេះ អាចឈានបន្តទៅដំណាក់កាលនៃការប្តូរជាប្រាក់បាន ដោយមិនបាច់ធ្វើនីតិវិធីដដែលសម្រាប់ការអនុវត្តដោយបង្ខំទេ។ ប៉ុន្តែ យ៉ាងណាក៏ដោយ បើជាការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដែលតម្រូវឲ្យមានការចុះបញ្ជីអំពីការរឹបអូស ដាច់ដោយឡែកពីការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នោះត្រូវមានដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ របស់តុលាការដែលមានសមត្ថកិច្ច។ ក្នុងករណីដែលម្ចាស់បំណុលមានការធ្វេសប្រហែសមិនបានដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំ បើទោះបីជាគ្រប់ល័ក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំ ត្រូវបានបំពេញហើយក៏ដោយនោះ កូនបំណុលអាចដាក់ពាក្យសុំឲ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយសារការផ្លាស់ប្ដូរស្ថានភាពបាន ដោយសំអាងទៅលើការលក់នៃភាពចាំបាច់នៃការរឹបអូសជាបណ្ដោះអាសន្ន[៩០] ។

[៩០] មាត្រា ៥៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

# សន្និដ្ឋាន

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងការពារ និង ថែរក្សាស្ថានភាពបច្ចុប្បន្ន ដោយប្រើអំណាចរបស់រដ្ឋ ដើម្បីការពារសិទ្ធិរបស់បុគ្គលណាម្នាក់ នៅពេលដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំ និង មិនអាចធ្វើបាន ឬ មានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុល នៃការអនុវត្ត ឬ នៅពេលដែលមានការបារម្ភថា និង មានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ ដល់ឋានៈរបស់ភាគីណាមួយ ដោយមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ។ ជាការពិត ការចាប់ផ្តើមការអនុវត្តដោយបង្ខំ តម្រូវឲ្យបំពេញល័ក្ខខណ្ឌដូចជាអត្ថិភាពនៃលិខិតអនុវត្ត និង ការមកដល់នៃពេលកំណត់សង ជាអាទិ៍។ ក៏ប៉ុន្តែទោះជាការអនុវត្តដោយបង្ខំ មិនអាចចាប់ផ្តើមបានបើខ្វះល័ក្ខខណ្ឌណាមួយក៏ដោយ ក៏ត្រូវតែទប់ស្កាត់ជាមុន មិនឲ្យមានការប្រែប្រួលផ្លូវច្បាប់ និង ស្ថានភាពជាក់ស្តែងដែរ ក្នុងករណីដែលការសម្រេចសិទ្ធិទាមទារដោយការអនុវត្តដោយបង្ខំ ទំនងជាមិនអាចធ្វើទៅបាន ឬ ទំនងជាមានការលំបាកយ៉ាងខ្លាំងនៅពេលដែលគ្រប់ល័ក្ខខ័ណ្ឌទាំងអស់សម្រាប់ការអនុវត្ត ត្រូវបានបំពេញនាពេលអនាគត ប្រសិនបើកូនបំណុលត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពដោយសេរីនោះ។

ការចាត់ចែងរក្សាការពាររួមមាន ការរឹបអូសជាបណ្តោះអាសន្ន និង ការចាត់ចែងជាបណ្តោះអាសន្ន។ ការចាត់ចែងជាបណ្តោះអាសន្ន ចែកជាការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន។ ការរឹបអូសជាបណ្តោះអាសន្ន ធ្វើឡើងក្នុងករណីសិទ្ធិដែលត្រូវបានរក្សាការពារ គឺជាសិទ្ធិទាមទារឲ្យសងជាប្រាក់។ ចំណែកឯកាចាត់ចែងជាបណ្តោះអាសន្ន ធ្វើឡើងក្នុងករណីសិទ្ធិដែលត្រូវការរក្សាការពារ គឺជាសិទ្ធិក្រៅពីសិទ្ធិទាមទារឲ្យសងជាប្រាក់។ ទោះជាយ៉ាងណាក៏ដោយ បើនិយាយអំពីមុខងារ ការរឹបអូសជាបណ្តោះអសន្ន និង ការចាត់ចែងជាបណ្តោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ មានលក្ខណៈរួមត្រង់ថា វិធានការទាំងពីរនេះ គឺជាការចាត់ចែងដែលមានគោលបំណងរក្សាការពារ នូវស្ថានភាពបច្ចុប្បន្នសំរាប់ការអនុវត្តដោយបង្ខំនាពេលអនាគត។ ដោយឡែកការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន មានលក្ខណៈខុសប្លែកពីនេះ ដោយវាបង្កើតឲ្យមាននូវឋានៈជាបណ្តោះអាសន្នរហូតដល់ពេលកំណត់ទំនាក់ទំនងនៃសិទ្ធិជាស្ថាពរ ក្នុងគោលបំណងដកចេញ និង ទប់ស្កាត់នូវគ្រោះថ្នាក់ និង ការលំបាកនាពេលបច្ចុប្បន្ន ដែលបង្ករឡើងដោយភាពយឺតយ៉ាវ នៃការកំណត់ទំនាក់ទំនងនៃសិទ្ធិនោះជាស្ថាពរ។

ការបែកចែកដំណាក់កាលនៅក្នុងនីតិវិធីចាត់ចែងរក្សាការពារ ៖ ជាទូទៅ នីតិវិធីចាត់ចែងរក្សាការពារមានចរិកលក្ខណៈជានីតិវិធីដែលបំពេញបន្ថែមទៅលើការអនុវត្ត ដោយបង្ខំដែលនៅក្នុងនោះ

មានការបែងចែកជាពីរដំណាក់កាលដូចតទៅ ៖ នីតិវិធីនៃការសម្រេចសេចក្តីដែលវិនិច្ឆ័យទៅលើភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃពាក្យសុំឲ្យចេញដីការសម្រេចរក្សាការពារ និង នីតិវិធីនៃការអនុវត្ត ដែលសម្រេចដោយបង្ខំនូវខ្លឹមសារនៃដីការសម្រេចរក្សាការពារ ដែលបានចេញដោយយកដីការសម្រេចនេះមកធ្វើជាលិខិតអនុវត្ត។ ដំណាក់កាលទី១ អាចហៅថាការសម្រេចរក្សាការពារ ឯដំណាក់កាលទីពីរ អាចហៅថាការអនុវត្តរក្សាការពារ។ ការបែងចែកនេះមានលក្ខណៈដូចគ្នា និង ការបែងចែករវាងនីតិវិធីបណ្តឹង និង នីតិវិធីនៃការអនុវត្តដោយបង្ខំដែរ។ ក៏ប៉ុន្តែគោលបំណងនៃដីកាសម្រេចរក្សាការពារអាចសម្រេចបានលុះណាតែមានការអនុវត្តដោយបង្ខំ ហេតុនេះហើយទំនាក់ទំនងរវាងការសម្រេចរក្សាការពារ និង ការអនុវត្តរក្សារការពារ មានលក្ខណៈជិតស្និទ្ធិជាងទំនាក់ទំនងរវាងនីតិវិធីបណ្តឹង និង វីតិវិធីនៃការអនុវត្តដោយបង្ខំ។

ការអនុវត្តរក្សាការពារ ៖ ការអនុវត្តរក្សារការពារត្រូវធ្វើឡើងដោយតុលាការ ឬ អាជ្ញាសាលាតាមពាក្យសុំ។ តុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារត្រូវ ហៅថាតុលាការអនុវត្តការរក្សាការពារ។ ការសម្រេចសេចក្តីដែលទាក់ទង និង នីតិវិធីដែលតុលាការធ្វើចំពោះការអនុវត្តរក្សាការពារត្រូវធ្វើឡើងដោយដីកាសម្រេច។ បើយល់ឃើញថា ចាំបាច់នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តរក្សាការពារអាចសួរ ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ឬ ជនដែលពាក់ព័ន្ធផ្សេងទៀតបាន។ បញ្ញត្តិមួយចំនួនស្តីពីការអនុវត្តដោយបង្ខំដែលស្ថិតនៅក្នុងគន្ថីទី៦ ជំពូកទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការអនុវត្តរក្សាការពារ លើកលែងតែមានបញ្ញត្តិពិសេស។

## អនុសាសន៍

ដោយហេតុថានៅតែមានចំណុចខ្វះចន្លោះនៅឡើយ ទាក់ទងនឹងនីតិវិធីនៃដំណើរការក្នុងរឿងរដ្ឋប្បវេណី សម្រាប់ប្រជាជនមួយភាគធំ ទោះបីជាប្រទេសយើងមាន ក្រមនីតិវិធីរដ្ឋប្បវេណី និង ក្រមរដ្ឋប្បវេណីក៏ដោយ ក៏ក្រមនេះបានចាប់ផ្តើមអនុវត្តបានប៉ុន្មានឆ្នាំហើយ ឃើញថានៅមានភាពមិនទាន់យល់ច្បាស់ដល់ប្រជាពលរដ្ឋទូទាំងប្រទេសនោះទេ។ ហេតុដូច្នេះយើងខ្ញុំសូមអនុញ្ញាតជូនជាអនុសាសន៍ដូចខាងក្រោម ៖

+ ក្រសួងយុត្តិធម៌ ៖

- ត្រូវបង្កើន និង ពង្រីកការផ្សព្វផ្សាយអំពីប្រព័ន្ធច្បាប់ឲ្យបានច្រើន ទាំងនីតិវិធី និង ក្រមក្នុងរឿងរដ្ឋប្បវេណី និង ព្រហ្មទណ្ឌ។
- បង្កើតឲ្យមានការផ្សព្វផ្សាយ និង ឲ្យមានសិក្ខាសាលាស្តីអំពី ប្រព័ន្ធច្បាប់នៅកម្ពុជា និង នីតិវិធីក្នុងរឿងក្តីឲ្យប្រជាពលរដ្ឋ ក៏ដូចជាអ្នកច្បាប់បានយល់គ្រប់គ្នាឲ្យរឹតតែច្បាស់។

- ធ្វើការផ្សព្វផ្សាយជារឿយៗតាមរយៈ វិទ្យុ ទូរទស្សន៍ ជាពិសេស ការចុះដល់មូលដ្ឋាននៃផ្ទះគាត់ដោយផ្ទាល់ ឲ្យបានច្រើន។
- បង្កើតជាឈុតរឿងខ្លីៗ អប់រំអំពីសិទ្ធិ និង កាតព្វកិច្ច តាមផ្លូវបណ្ដឹង រួមទាំងផ្សព្វផ្សាយឲ្យបានទូលាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា។
- ជម្រុញសមត្ថភាពអ្នកអនុវត្តច្បាប់ផ្សេងៗទៀត បានសិក្សា និង ពង្រីកសមត្ថភាពរបស់ខ្លួន ជាពិសេសចៅក្រម គឺបណ្ដុះបណ្ដាលឲ្យច្បាស់លាស់ពីចៅក្រមម្នាក់ៗឲ្យមានជំនាញលើរឿងមួយឲ្យច្បាស់ដាច់ពីគ្នា។ ឧទាហរណ៍ ចៅក្រមផ្នែកព្រហ្មទណ្ឌ រដ្ឋប្បវេណី ផ្នែកការងារ ផ្នែករដ្ឋបាល។
- ជម្រុញនិងខិតខំបង្កើតឲ្យមានតុលាការឲ្យចំជំនាញរបស់ខ្លួន ដើម្បីឲ្យមានការទុកចិត្តខ្ពស់ពីសំណាក់ប្រជាពលរដ្ឋ។

+អង្គការជាតិ និង អន្តរជាតិដែលពាក្យព័ន្ធលើវិស័យច្បាប់ ៖

- សូមមេត្តាចុះពន្យល់ អប់រំ ណែនាំ ប្រជាពលរដ្ឋតាមមូលដ្ឋានដោយផ្ទាល់៕

# ឯកសារយោង

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

- ច្បាប់ស្តីពី នីតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០

- ច្បាប់ស្តីពី នីតិវិធីបណដឹងដែលទាក់ទងនឹងឋានៈបុគ្គល ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០

- សារាចរលេខ ០៤ សចរ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៨៤ របស់ក្រសួងយុត្តិធម៌ ស្តីពី "សេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី"

- វចនានុក្រមរបស់សម្តេចសង្ឃរាជ ជួន ណាត បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យឆ្នាំ១៩៦៨

- សន្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី របស់ទីស្តីការគណរដ្ឋមន្ត្រីបោះពុម្ពលើទី១ ឆ្នាំ២០០៧

- សៀវភៅសេចក្តីពន្យល់អំពី "ក្រមនីតិវិធីរដ្ឋប្បវេណី" ភាគ១ នីតិវិធីបណ្តឹង របស់ក្រសួងយុត្តិធម៌ បោះពុម្ពក្នុងឆ្នាំ២០០៨

- សៀវភៅសេចក្តីពន្យល់អំពី "ក្រមនីតិវិធីរដ្ឋប្បវេណី" ភាគ២ ការអនុវត្តដោយបង្ខំ របស់ក្រសួងយុត្តិធម៌ បោះពុម្ពក្នុងឆ្នាំ២០០៨

- សៀវភៅ "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី" របស់ក្រសួងយុត្តិធម៌ បោះពុម្ពនៅឆ្នាំ២០០៧

- សៀវភៅមេរៀនស្តីពី "នីតិរដ្ឋប្បវេណី" របស់លោកសាស្ត្រាចារ្យ ញឹក វុទ្ធី ឆ្នាំសិក្សា ២០០៦-២០០៧

- សៀវភៅណែនាំ "ច្បាប់រដ្ឋប្បវេណី" (ករណីប្រទេសជប៉ុន) និពន្ធដោយ អ៊ីកិដា ម៉ាសាអូ ប្រែសម្រួលដោយ គង់ ទេសី បោះពុម្ពនៅខែធ្នូ ឆ្នាំ២០០៧

- សៀវភៅ សំណួរដែលត្រូវបានគេសួរញឹកញាប់ ស្តីពីការចាត់ចែងរក្សាការពារ របស់កម្មវិធីប្រសិទ្ធិភាពនៃការបណ្តោះបណ្តាលផ្នែករដ្ឋប្បវេណី នៅសាលាភូមិន្ទថៅក្រម បោះពុម្ពនៅខែឧសភា ឆ្នាំ២០១០

- សៀវភៅអត្ថាធិបាយ កម្រងច្បាប់ខ្មែរ "អំពីក្រមរបៀបក្តី ផ្នែករដ្ឋប្បវេណី" រៀបរៀងដោយបណ្ឌិត ស សូវាន ដែលត្រូវបានប្រែសម្រួល ពីក្រមខ្មែរ ជាភាសាបារាំង បោះពុម្ពផ្សាយនៅឆ្នាំ១៩៦៥

- សៀវភៅ "នីតិគ្រួសារ និង អាពាហ៍ពិពាហ៍" ភាគ១ ឆ្នាំ២០១៣ របស់លោក សាស្ត្រាចារ្យ ឥន យឿន បោះពុម្ព ដោយរោងពុម្ព (ISB) ក្នុងឆ្នាំ២០១២

- សៀវភៅអត្ថាធិប្បាយច្បាប់ ភាគ៣ "ក្នុងរឿងរដ្ឋប្បវេណី សម្រាប់ប្រជាជនសាមញ្ញ" របស់លោក ហ៊ីង ធីឬទ្ធិ បោះពុម្ពលើកទី ២ ឆ្នាំ២០០៧

- សៀវភៅមេរៀន នីតិវិធីរដ្ឋប្បវេណី របស់សាស្ត្រាចារ្យ អ៊ឹង ប៉ូលី ឆ្នាំសិក្សា២០១០-២០១១